ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ

# ORGANIZATIONAL CITIZENSHIP BEHAVIOR OF HIGH SCHOOL TEACHERS IN PHNOM PENH

ដោយ/by

ហ៊ឹម ម៉ាណា/HIM MANA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩
ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យ ក្នុងរាជធានីភ្នំពេញ

# ORGANIZATIONAL CITIZENSHIP BEHAVIOR OF HIGH SCHOOL TEACHERS IN PHNOM PENH


ដោយ/by

**ហ៊ីម ម៉ាណា/HIM MANA**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២០-២០២២

គ្រូណែនាំបង្គោល ៖ លោក ថៃ ហេង

គ្រូណែនាំរង ៖ ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម

# សេចក្ដីអះអាងរបស់បេក្ខជន

នាងខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា “**ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀន កម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ**” សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃ ច័ន្ទ ២ រោច ខែ ភទ្របទ ឆ្នាំខាល ចត្វាសក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០២២

**ហត្ថលេខា**



**ហ៊ឹម ម៉ាណា**

# លិខិតបញ្ជាក់ពីគ្រូណែនាំ

លោក **ថៃ ហេង** ជាគ្រូណែនាំបង្គោល

ឯកឧត្តមបណ្ឌិត **ម៉ុក សារ៉ុម** ជាគ្រូណែនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

អ្នកស្រី **ហ៊ីម ម៉ាណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអត្តភាពរបស់គ្រូបង្រៀន កម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ**" ពិតប្រាកដមែន។

ថ្ងៃ ច័ន្ទ ២ រោច ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០២២

**ថៃ ហេង**

នាយករងវិទ្យាស្ថានជាតិអប់រំ

**ម៉ុក សារ៉ុម**

អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ

# លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៦៣៧៤.១ អយក.វ៤៧

ថ្ងៃ សុក្រ ១៣កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ មេសា ឆ្នាំ២០២២

**ជម្រាបជូន**
**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩។

**យោង៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រប់អប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រីប្រធាន ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ចំនួន៥៨នាក់ នឹងចុះប្រមូលទិន្នន័យនៅតាមរាជធានីខេត្តនានា ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

អាស្រ័យហេតុនេះ សូម លោក លោកស្រីប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រីប្រធាន ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអយក "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១០ ៦៧៣ / ២២០ ៣០៤ ទូរសារ៖ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២៣៤១ អយក.វដក

[illegible] ១២ ឧសភា ២២
[illegible] ២១២
[illegible] ជស្យ

ថ្ងៃ សុក្រ ១៣រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០២២

**ជម្រាបជូន**
**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩។

**យោង៖** - បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រប់អប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រីប្រធាន ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ចំនួន៥៨នាក់ នឹងចុះប្រមូលទិន្នន័យនៅតាមរាជធានីខេត្តនានា ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

អាស្រ័យហេតុនេះ សូម លោក លោកស្រីប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រីប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអយក "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ [illegible] ទូរសារ [illegible]
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លេខ ០១៧ ចល.អយក.ភព

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម

និងបញ្ជូនមក៖

-ការិយាល័យនៃមន្ទីរអយក.ភ (ពាក់ព័ន្ធ)

-ការិយាល័យ អយក.ខណ្ឌ(ពាក់ព័ន្ធ)

" ដើម្បីជាព័ត៌មាន-មុខការ "

-វិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែនសំរោង -ឫស្សីកែវ -ប៊ុនរ៉ានីហ៊ុនសែនកោះដាច់ -បឹងធំ -ច្បារអំពៅ និងចំរើនផល

" ដើម្បីចូលរួមផ្តល់ការសម្របសម្រួលក្នុងការប្រមូលទិន្នន័យរបស់កម្មសិក្សាការី "

-លោកស្រីហ៊ឹម ម៉ាណា " ដើម្បីអនុវត្ត "

-ឯកសារកាលប្បវត្តិ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០២២

ជ. ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ

អនុប្រធាន

ហោច.សារិទ

# លិខិតអនុញ្ញាតឱ្យឡើងការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

គោរពជូន
ឯកឧត្តមបណ្ឌិតនាយក វិទ្យាស្ថានជាតិអប់រំ

| | | |
|---|---|---|
| អនុញ្ញាតឲ្យនិស្សិតឈ្មោះ | ៖ | ហ៊ឹម ម៉ាណា |
| ប្រធានបទស្រាវជ្រាវ | ៖ | ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យ ក្នុងរាជធានីភ្នំពេញ |
| ដើម្បីចូលរួម | ៖ | ការពារនិក្ខេបបទសាកល្បងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ |
| កាលបរិច្ឆេទការពារសាកល្បង | ៖ | ថ្ងៃទី... ខែតុលា ឆ្នាំ២០២២ ម៉ោង.............នាទីព្រឹក |
| ទីកន្លែង | ៖ | វិទ្យាស្ថានជាតិអប់រំ |

យើងខ្ញុំជាសាស្ត្រាចារ្យដឹកនាំ និងដឹកនាំរង ពិតជាបានអនុញ្ញាតឱ្យ និស្សិតមានឈ្មោះខាងលើបានចូលរួមការពារនិក្ខេបបទសាកល្បង ដើម្បីបំពេញក្របខ័ណ្ឌការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ឆ្នាំសិក្សា ២០២០ - ២០២២ តាមការកំណត់របស់វិទ្យាស្ថានជាតិអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ខែតុលា ឆ្នាំ២០២២

សាស្ត្រាចារ្យដឹកនាំ

លោក ថៃ ហេង

សាស្ត្រាចារ្យដឹកនាំរង

ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម

# មូលន័យសង្ខេប

ការសិក្សាអំពីឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀន មានគោលបំណងពីរសំខាន់៖ (១) ស្វែងយល់ពីទស្សនៈរបស់គ្រូបង្រៀកម្រិត វិទ្យាល័យ ក្នុងរាជធានីភ្នំពេញ លើឥរិយាបថក្នុងអង្គភាព ទាំង៥ផ្នែក មានឧត្តមគតិការងារ អត្តទត្ថបុគ្គល និយ័តភាពការងារ ភាពបម្រុងប្រយ័ត្ន និងមនុស្សធម៌ការងារ និង (២) វាស់ស្ទង់ឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាម ភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍ការបង្រៀន។

ប្រជាជនដែលប្រើក្នុងការស្រាវជ្រាវនេះ គឺគ្រូបង្រៀនកម្រិតវិទ្យាល័យដែលរាប់បញ្ចូលពីថ្នាក់ទី ៧ ដល់ ថ្នាក់ទី១២ នៅក្នុងរាជធានីភ្នំពេញចំនួន ២២៧នាក់ ដែលរើសចេញពីសាលាចំនួន៦ ដែលស្ថិតក្នុងខណ្ឌចំនួន៦ផ្សេងគ្នា ក្នុងនោះមាន វិទ្យាល័យឫស្សីកែវស្ថិតក្នុងខណ្ឌឫស្សីកែវ វិទ្យាល័យសម្តេចតេជោហ៊ុនសែនសំរោងស្ថិតក្នុងខណ្ឌព្រែកព្នៅ វិទ្យាល័យហ៊ុនសែនកោះដាច់ស្ថិតក្នុងខណ្ឌជ្រោយចង្វារ វិទ្យាល័យបឹងធំស្ថិតក្នុងខណ្ឌកំបូល វិទ្យាល័យច្បារអំពៅស្ថិតក្នុងខណ្ឌច្បារអំពៅ និងវិទ្យាល័យចំរើនផលស្ថិតក្នុងខណ្ឌមានជ័យ។ ស្ថិតិដែលប្រើសម្រាប់ប្រមូលទិន្នន័យ គឺជាកម្រងសំណួរ ផ្នែកទី១ដែលពាក់ព័ន្ធនឹងព័ត៌មានអំពីស្ថានភាពទូទៅរបស់លោកគ្រូអ្នកគ្រូ មានដូចជា ភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍បង្រៀន។ ផ្នែកទី ២ ទស្សនៈគ្រូបង្រៀនទៅលើការអនុវត្តឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព។ ស្ថិតិដែលប្រើក្នុងការវិភាគទិន្នន័យមានដូចជា ភាគរយ តម្លៃមធ្យម គម្លាតស្តង់ដា Independent Sample t-test, One-way ANOVA និង ការប្រៀបធៀបដោយប្រើវិធីសាស្ត្រ Scheffe ។

លទ្ធផលសំខាន់ៗនៃការសិក្សាស្រាវជ្រាវនេះ អាចសរុបបានដូចខាងក្រោម៖

១- ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ជារួមស្ថិតក្នុងកម្រិត "**ខ្ពស់**"។ ពេលពិចារណាតាមផ្នែក លទ្ធផលស្ថិតក្នុងកម្រិត "**ខ្ពស់**" គ្រប់ផ្នែក។ បើលំដាប់តម្លៃមធ្យមពីខ្ពស់មកទាប គឺផ្នែកអត្តទត្ថបុគ្គល ស្ថិតក្នុងលំដាប់ទី១ តាមដោយផ្នែកនិយ័តភាពការងារ ស្ថិតក្នុងលំដាប់លេខ២ បន្តមកផ្នែកមនុស្សធម៌ការងារ ស្ថិតក្នុងលំដាប់លេខ៣ បន្ទាប់មកផ្នែកឧត្តមគតិការងារ ស្ថិតក្នុងលំដាប់លេខ៤ និងផ្នែកភាពបម្រុងប្រយ័ត្ន ស្ថិតក្នុងលំដាប់លេខ៥។

ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យដោយបែងចែកតាមភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍បង្រៀន ស្ថិតក្នុងកម្រិត "**ខ្ពស់**"។

២- លទ្ធផលប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញដែលមានភេទដូចគ្នាបានបង្ហាញឱ្យឃើញថា គ្រូបង្រៀនដែលមានភេទដូចគ្នាមានការយល់ឃើញខុសគ្នាយ៉ាងមានសារៈសំខាន់ផ្នែកស្ថិតតិក្នុងកម្រិត ០.០១ ចំណែកឯផ្នែកដទៃទៀតមិនខុសគ្នានោះទេ។ បើធ្វើការប្រៀបធៀបទៅលើអាយុវិញនោះ លទ្ធផលបង្ហាញថា ផ្នែកនិយ័តភាពការងារមានភាពខុសគ្នាយ៉ាងមានសារៈសំខាន់ផ្នែកស្ថិតតិក្នុងកម្រិត ០.០១ ឯផ្នែកទាំង៤ទៀត ពុំមានភាពខុសគ្នានោះទេ។ បន្ថែមពីនេះទៅទៀត បើយើងមើលទៅលើលទ្ធផលប្រៀបធៀបទៅលើកម្រិតគុណវុឌ្ឍិគ្រូបង្រៀនវិញ នោះយើងឃើញ ការយល់ឃើញគ្រប់ផ្នែកទាំង៥របស់គ្រូបង្រៀនគឺមានភាពដូចគ្នា។ រីឯការបង្រៀបធៀបទៅតាមបទពិសោធន៍បង្រៀនវិញ លទ្ធផលបង្ហាញឱ្យឃើញថាផ្នែកនិយ័តភាពការងារ ផ្នែកបម្រុងប្រយ័ត្ន និងផ្នែកមនុស្សធម៌ការងារមានភាពខុសគ្នាយ៉ាងមានសារៈសំខាន់ផ្នែកស្ថិតិក្នុងកម្រិត ០.០១ ចំណែកឯ២ផ្នែកដទៃផ្សេងទៀតគឺ ផ្នែកឧត្តមគតិការងារ និងផ្នែកអត្តទត្តបុគ្គលមិនមានភាពខុសគ្នានោះទេ។

# Abstract

The purposes of this research were: (1) to understand the views of high school teachers in Phnom Penh on organizational citizenship behavior of the five main themes such as: Conscientiousness, Sportsmanship, Civic virtue, Courtesy, and Altruism (2) measure the organizational citizenship behavior of high school teachers in Phnom Penh by gender, age, qualification, and experiences.

The sample used in this study was 227 high school teachers in Phnom Penh city from grade 7 to grade 12. The 6 schools were selected from 6 different districts including Russey Keo high school in Russey Keo district, Hun Sen Samdach Decho SamRong in Prek Phnov district, BeoungThom high school in Kombol district, Chbar Ampov high school in Chbar Ampov district and Chamroeunphal high school in Meanchey district. The tools used in this study were a questionnaire on the of organization citizenship behavior of high school teacher scale from Bateman and Organ 1983. Statistics used to analyze data by percentage, mean, standard deviation, Independent Sample t-test, One-way ANOVA, comparing pairs using the Scheffe's method.

The research results were summarized as follows:

1. The organizational citizenship behavior of high school teacher in Phnom Penh in generally "high. When considered in terms of the results are "high" in all respects. If the average value is from high to low, the result was: Sportsmanship, Civic virtue, Altruism, Conscientiousness and Courtesy. Organizational citizenship behavior of high school teacher by gender, age, qualifications and experience is at a "high" level in all parts.

2. Results of Comparison of Perception of high school teacher in Phnom Penh showed that teachers of the same sex had a statistically significant difference of view at the 0.01 level, while other sections did not differ. Comparing age, the results showed that there was a statistically significant difference in employment regulation at 0.01, while the other four did not. In addition, if we look at the results comparing the qualifications of teachers, we see that all five perceptions of teachers were the same. Comparing the teaching experience, the results showed that the civic virtue, courtesy and altruism were statistically significant at the 0.01 level, while the other two divisions were not.

# លិខិតថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវមួយនេះ បានសម្រេចដល់គោលដៅប្រកបដោយភាពជោគជ័យ ក៏ព្រោះតែមានការចូលរួមពីសំណាក់បុគ្គលសំខាន់ៗពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធនានាជាច្រើន ដែលបានចូលរួមសម្របសម្រួល និងជ្រោមជ្រែងយ៉ាងយកចិត្តទុកដាក់បំផុត តាំងពីពេលចាប់ផ្ដើមរហូតដល់ទីបញ្ចប់។ កត្តាទាំងនេះហើយបានធ្វើឱ្យនាងខ្ញុំ មានសេចក្ដីសោមនស្សក្រៃលែង និងមានភាពកក់ក្ដៅជាខ្លាំងនឹងរកអ្វីមកថ្លែងពុំបាន ក្នុងដំណើរការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ។

ជាដំបូង នាងខ្ញុំសូមលើកម្រាមដៃដប់បង្ហាញនូវសេចក្ដីដឹងគុណយ៉ាងធំពេកក្រៃលែងដែលគ្មានអ្វីប្រៀបផ្ទឹមបាន ទៅចំពោះព្រះរស់ទាំងពីរអង្គគឺ លោកឪពុក និងអ្នកម្ដាយរបស់ខ្ញុំ ដែលបានផ្ដល់កំណើតដល់រូបនាងខ្ញុំ ហើយថែមទាំងខិតខំបីបាច់ថែរក្សា ផ្គត់ផ្គង់គ្រប់បែបយ៉ាង ផ្ដល់ដំបូន្មាន និងឱកាសឱ្យកូនស្រីម្នាក់នេះបានរៀនសូត្រតាំងពីថ្នាក់ដំបូងរហូតមកដល់កម្រិតមួយនេះ និងរហូតទទួលបានផលប្រកបដោយផ្លែផ្កា។

ក្រៅពីឪពុកម្ដាយមក គឺលោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលជាអ្នកមានគុណទីពីរ ដែលបានបង្ហាត់បង្រៀននាងខ្ញុំតាំងពីបឋមរហូតឥឡូវ ដោយលោកបានចំណាយអស់កម្លាំងកាយចិត្តស្មារតី និងពេលវេលាបង្ហាត់បង្រៀន និងអប់រំរូបនាងខ្ញុំមិនគិតពីការលំបាកនឿយហត់ ទោះបីពេលខ្លះលោកអ្នកទាំងអស់កំពុងមានបញ្ហាផ្សេងៗផ្ទាល់ខ្លួនក៏ដោយ។ មិនតែប៉ុណ្ណោះ លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូតែងតែយកចិត្តទុកដាក់ ប្រៀនប្រដៅណែនាំ លើកទឹកចិត្តឱ្យបន្តការសិក្សារហូតមក ក៏ព្រោះថាចំណេះដឹងជាទ្រព្យសម្បត្តិដ៏វិសេសវិសាលបំផុតប្រសើរលើសទ្រព្យសម្បត្តិទាំងពួង ដែលមិនចេះរីងស្ងួត ចោរលួចមិនបាន ភ្លើងក៏មិនឆេះ កណ្ដៀរមិនកោរ កណ្ដុរមិនកាត់។

ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំបង្កើតឡើងនូវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នេះឡើយក្រោមការគ្រប់គ្រងយ៉ាងល្អឥតខ្ចោះពីសំណាក់គណៈគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់

បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិអប់រំទាំងអស់ ដែលបាន ចំណាយពេលវេលាយ៉ាងមមារញឹក និងមានតម្លៃបង្ហាត់បង្រៀនដល់នាងខ្ញុំ ដោយមិនគិតពីការនឿយហត់។

គោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅចំពោះ លោក **ថៃ ហេខ** ជាសាស្ត្រាចារ្យណែនាំបង្គោល ដែលលោកតែងតែលៃលកពេលវេលាដ៏មានតម្លៃឆ្លៀតក្នុងការជួយកែសម្រួល រចនាបទ ឃ្លាប្រយោគ និង របៀបសរសេរនិក្ខេបបទ ព្រមទាំងជួយកែសម្រួលកម្រងសំណួរផ្សេងៗទាក់ទងនឹងប្រធានបទ និងការវិភាគ ទិន្នន័យផងដែរ។ មិនតែប៉ុណ្ណោះលោកក៏បានផ្តល់ជាឯកសារទាក់ទងនឹងប្រធានបទ និងជួយបង្ហាញទិសដៅ ដល់រូបនាងខ្ញុំផងដែរ។

គោរពថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ទៅចំពោះ ឯកឧត្តមបណ្ឌិត **ម៉ុក សារ៉ុម** ជាសាស្ត្រាចារ្យណែនាំ រង ដែលលោកជាកតាលីករសំខាន់បំផុតសម្រាប់នាងខ្ញុំ ទាំងក្នុងដំណើរការសិក្សារៀនសូត្រ និងដំណើរការ សិក្សាស្រាវជ្រាវមួយនេះ។ ឯកឧត្តមតែងតែឆ្លៀតពេលវេលាដ៏សែនរវល់របស់លោក មកបង្ហាត់បង្ហាញ ផ្តល់ជា អនុសាសន៍ណែនាំល្អៗ ជួយកែលម្អរាល់ចំណុចខ្វះខាតទាំងឡាយទាំងពាក្យពេចន៍ឃ្លាប្រយោគ ទាំងអក្ខរាវិរុទ្ធ និងផ្តល់កម្លាំងចិត្ត បច្ចេកទេស វិធីសាស្ត្រនានាក្នុងការរៀបរៀងនិក្ខេបបទនេះ។

មិត្តរួមថ្នាក់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ទាំងអស់ ដែលតែងតែផ្តល់ការលើកទឹកចិត្តដល់រូបនាងខ្ញុំ តាមរយៈការចែករំលែកចំណេះដឹង បទពិសោធន៍ ផ្តល់ជូននូវរាល់ព័ត៌មាន និងចែករំលែកឯកសារពាក់ព័ន្ធ នានា ធ្វើឱ្យនាងខ្ញុំមានទឹកចិត្តតស៊ូព្យាយាម និងអាចពុះពារជំនះរាល់ការលំបាកគ្រប់ឧបសគ្គទាំងឡាយរហូត សម្រេចគោលដៅនៃការស្រាវជ្រាវសរសេរនិក្ខេបបទនេះ។

គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមឆ្លើយនូវកម្រង សំណួរ និងសហការក្នុងការផ្តល់ទិន្នន័យធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

អរគុណយ៉ាងខ្លាំងទៅចំពោះស្វាមី ដែលបានខិតខំជួយយ៉ាងសកម្មក្នុងដំណើរការប្រមូលទិន្នន័យនៅ តាមបណ្តាសាលា និងផ្តល់ជាកម្លាំងចិត្តដល់ភរិយាមួយនេះឱ្យដើរឆ្លងផុតនូវដំណាក់កាលពិបាកៗជាច្រើន។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពរំលឹកនឹកគុណព្រះរតនត្រ័យ "ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ" សូមជួយតាមថែរក្សាលោកអ្នកមានគុណទាំងទ្វេ ឯកឧត្តម លោកជំទាវ លោក លោកស្រីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ លោកគ្រូ អ្នកគ្រូ និងមិត្តភក្តិទាំងអស់ សូមជួបប្រទះតែសេចក្តីសុខចម្រើន សុវត្ថិភាព សុខភាពល្អបរិបូណ៌ សម្រេចជោគជ័យគ្រប់ភារកិច្ច និងសេចក្តីប៉ងប្រាថ្នា ព្រមទាំងទទួលបាននូវពុទ្ធពរទាំងឡាយ ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មាតិកា


**សេចក្តីអះអាងរបស់បេក្ខជន** ..... i

**លិខិតបញ្ជាក់ពីគ្រូណែនាំ** ..... ii

**លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ** ..... iii

**លិខិតអនុញ្ញាតឱ្យឡើងការពារនិក្ខេបបទ** ..... vi

**មូលន័យសង្ខេប** ..... vii

**លិខិតថ្លែងអំណរគុណ** ..... xi

**ជំពូកទី១៖ សេចក្តីផ្តើម** ..... 2

១.១- លំនាំបញ្ហានៃការស្រាវជ្រាវ ..... 2

១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ ..... 4

១.៣- គោលបំណងនៃការស្រាវជ្រាវ ..... 5

១.៤- សំណួរស្រាវជ្រាវ ..... 5

១.៥- សារៈសំខាន់នៃការស្រាវជ្រាវ ..... 6

១.៦- វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ..... 7

១.៦.១- ផ្នែកខ្លឹមសារ ..... 7

១.៦.២- ប្រជាជន និងភាគសំណាក ..... 8

១.៦.៣- អថេរនៃការសិក្សា ..... 8

១.៦.៤- រយៈពេលនៃការសិក្សា ..... 8

១.៧- និយមន័យពាក្យគន្លឹះនៃការស្រាវជ្រាវ ..... 8

១.៨- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... 9

**ជំពូកទី២៖ រំលឹកទ្រឹស្តី និងការស្រាវជ្រាវដែលពាក់ព័ន្ធ** ..... 12

២.១- បញ្ញត្តិ និងទ្រឹស្តីពាក់ព័ន្ធនឹងពលរដ្ឋសកលនិងឥរិយាបថភាពជាពលរដ្ឋសកល ..... 12

២.១.១- អត្ថន័យឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព ..... 12

២.១.២- ការអប់រំភាពជាពលរដ្ឋសកល ........................................................................ 16
២.១.៣- គោលបំណងការអប់រំភាពជាពលរដ្ឋសកល.................................................... 17
២.១.៤-សារៈប្រយោជន៍របស់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព........................20
២.១.៥- ការវិវត្តន៍នៃការសិក្សាឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព........................ 21
២.២- ការគ្រប់គ្រងតាមសាលា.........................................................................................24
២.២.១- និយមន័យការគ្រប់គ្រងតាមសាលារៀន.............................................................24
២.២.២- ការគ្រប់គ្រងតាមសាលារៀន ក្នុងបរិបទតំបន់និងសកលលោក..........................24
២.២.៣- ការគ្រប់គ្រងតាមសាលារៀនក្នុងបរិបទកម្ពុជា ..................................................28
២.២.៤-ភាពបន្ស៊ីគ្នារវាងការគ្រប់គ្រងអប់រំ និងគុណភាពពលរដ្ឋ ....................................29
២.២.៥-តួនាទីគ្រូបង្រៀនក្នុងបរិបទតំបន់ .................................................................33
២.២.៦-តួនាទីគ្រូបង្រៀនក្នុងបរិបទកម្ពុជា ..................................................................35
២.៣- ការស្រាវជ្រាវពាក់ព័ន្ធឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព ............................37
២.៣.១- ការរក្សាសិទ្ធិ ឬធន្មានុសិទ្ធិ ............................................................................37
២.៣.២-ចិត្តវិទ្យាវិជ្ជមាន...................................................................................................40
២.៣.៣-វិមាត្រនៃ OCB ....................................................................................................42
**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ**..........................................................................................47
៣.១- របៀបវិធីនៃការស្រាវជ្រាវ .........................................................................................47
៣.២- ប្រជាជននិងភាគសំណាកអង្កេតគោលដៅ...................................................................47
៣.២.១- ប្រជាជន .............................................................................................................47
៣.២.២- ភាគសំណាកគោលដៅ ........................................................................................48
៣.៣- ឧបករណ៍នៃការសិក្សាស្រាវជ្រាវ ...............................................................................50
៣.៣.១- ការបង្កើត និងទម្រង់នៃកម្រងសំណួរ ................................................................... 51
៣.៣.២- ការត្រួតពិនិត្យគុណភាពឧបករណ៍ .........................................................................55
៣.៤- វិធីសាស្ត្រប្រមូលទិន្នន័យ............................................................................................56
៣.៥- ការវិភាគទិន្នន័យនិងស្ថិតិដែលប្រើក្នុងការវិភាគ .........................................................57

៣.៥.១- ស្ថិតិដែលប្រើក្នុងការពិនិត្យគុណភាពឧបករណ៍....................58
៣.៥.២- អំណាចចំណែក (Discrimination)....................58
៣.៥.៣- ភាពជឿជាក់ ($\alpha$)....................59
៣.៥.៤- ស្ថិតិមូលដ្ឋាន....................59
៣.៦- ក្រមសីលធម៌នៃការស្រាវជ្រាវ....................60
**ជំពូកទី៤៖ លទ្ធផលនៃការស្រាវជ្រាវ និងពិភាក្សា**....................62
៤.១- លទ្ធផលការស្រាវជ្រាវ....................62
៤.១.១- លទ្ធផលការស្រាវជ្រាវទិន្នន័យផ្នែកទី១....................62
៤.១.២- លទ្ធផលការស្រាវជ្រាវទិន្នន័យផ្នែកទី២....................76
៤.២- ការពិភាក្សាលទ្ធផលស្រាវជ្រាវ....................80
៤.២.១- ទស្សនៈគ្រូបង្រៀនលើឥរិយាបថភាពជាពលរដ្ឋសកល....................80
៤.២.២- ការប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀន....................84
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**....................89
៥.១- សរុបលទ្ធផលការស្រាវជ្រាវ....................89
៥.២- សេចក្តីសន្និដ្ឋាន....................91
៥.៣- សំណូមពរ....................93
៥.៣.១- សំណូមពរសម្រាប់ក្រសួង និងអ្នករៀបចំគោលនយោបាយ....................93
៥.៣.២- សំណូមពរសម្រាប់អ្នកអនុវត្ត....................94
៥.៣.៣- សំណូមពរសម្រាប់អ្នកសិក្សាបន្ត....................94
**ឯកសារយោង**....................96
**ឧបសម្ព័ន្ធ**....................99

# បញ្ជីចំណងជើងតារាង


| ល.រ | ឈ្មោះតារាង | ទំព័រ |
|---|---|---|
| **តារាងទី២.១** | ចំណុចលេចធ្លោរមួយចំនួនរបស់អ្នកស្រាវជ្រាវ | 13 |
| **តារាងទី២.២** | ចំនួនអត្ថបទទាក់ទងនឹងឥរិយាបថភាពជាពលរដ្ឋសកល និងការស្រាវជ្រាវពាក់ព័ន្ធ | 23 |
| **តារាងទី៣.១** | ឈ្មោះខណ្ឌ ចំនួនសាលា និងចំនួនគ្រូ | 48 |
| **តារាងទី៣.២** | ចំនួន និងភាគរយរបស់ភាគសំណាក | 49 |
| **តារាងទី ៣.៣** | ផ្នែកចម្បងនិងផ្នែករងលើការប្រតិបត្តិឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព | 52 |
| **តារាងទី៣.៤** | ផ្នែក និងចំណុចនីមួយៗនៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព | 53 |
| **តារាងទី៣.៥** | តម្លៃអាល់ហ្វារបស់កម្រងសំណួរនីមួយៗ | 55 |
| **តារាងទី៤.១** | ចំនួនភាគសំណាកបែងចែកតាមភេទ | 62 |
| **តារាងទី៤.២** | ចំនួនភាគសំណាកបែងចែកតាមអាយុ | 63 |
| **តារាងទី៤.៣** | ចំនួនភាគសំណាកបែងចែកតាមគុណវុឌ្ឍិ | 63 |
| **តារាងទី៤.៤** | ចំនួនភាគសំណាកបែងចែកតាមបទពិសោធន៍ | 64 |
| **តារាងទី៤.៥** | តម្លៃមធ្យម គម្លាតស្តង់ដារ អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនតាមចំណុចនីមួយៗ | 64 |
| **តារាងទី៤.៦** | តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋសកលកក្នុងអង្គភាពតាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង៥ | 67 |

| | | |
|---|---|---|
| **តារាងទី៤.៧** | តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង៥ និងតាមចំណុចនីមួយៗ | 67 |
| **តារាងទី៤.៨** | តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព តាមទស្សនៈគ្រូបង្រៀនតាមផ្នែកទាំង ៥ ដោយបែងចែកតាមភេទ | 70 |
| **តារាងទី៤.៩** | តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង ៥ ដោយបែងចែកតាមអាយុ | 72 |
| **តារាងទី៤.១០** | តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង ៥ ដោយបែងចែកតាមគុណវុឌ្ឍិ | 73 |
| **តារាងទី៤.១១** | តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង ៥ ដោយបែងចែកតាមបទពិសោធន៍ការបង្រៀន | 74 |
| **តារាងទី៤.១២** | ការប្រៀបធៀបភាពខុសគ្នា និងដូចគ្នានៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព របស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមភេទ | 76 |
| **តារាងទី៤.១៣** | ការប្រៀបធៀបភាពខុសគ្នា និងដូចគ្នានៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព របស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមអាយុ | 77 |
| **តារាងទី៤.១៤** | ការប្រៀបធៀបភាពខុសគ្នា និងដូចគ្នានៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព របស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមគុណវុឌ្ឍិ | 78 |
| **តារាងទី៤.១៥** | ការប្រៀបធៀបភាពខុសគ្នា និងដូចគ្នានៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព របស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមបទពិសោធន៍បង្រៀន | 79 |

# បញ្ជីអក្សរកាត់

| | | ទំព័រ |
|---|---|---|
| **EMIS:** | Education Management Information System. | 8 |
| **UNESCO:** | United Nations Education, Scientific and Cultural Organization. | 9 |
| **OCB:** | Organizational Citizenship Behavior. | 14 |
| **SMI:** | School Management Initiatives. | 27 |
| **SBM:** | School Based Management. | 24 |
| **OXFAM:** | Oxford Committee for Famine Relief. | 31 |
| **IQ:** | Intelligence Quotient. | 31 |
| **SD:** | Standard Deviation. | 58 |
| **M:** | Mean. | 58 |

# ជំពូក១

# សេចក្ដីផ្ដើម

# ជំពូក១

# សេចក្តីផ្តើម

## ១.១- លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ឆ្លើយតបទៅនឹងបរិបទសកលលោក ដែលមានមហិច្ឆតា និងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាពអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត ក្នុងក្របខណ្ឌទូលំទូលាយគ្របដណ្តប់លើគ្រប់ប្រភេទ និងកម្រិតនៃការអប់រំ ជាពិសេស ស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ (ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០៣០)។

ជាមួយគ្នានេះដែរ ភាពជាពលរដ្ឋសកល និងការកើនឡើងនៃលក្ខខណ្ឌសម្រាប់ការប្រកួតប្រជែងក្នុងតំបន់បាននាំឱ្យមានការខិតខំស្វះស្វែង ស្វែងយល់ពីការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើតឱ្យបរិយាកាសការងារកាន់តែប្រសើរឡើង ឈានដល់ការបង្កើនគុណភាពការងារសម្រាប់អង្គភាព ទាំងក្នុងតំបន់ និងសកលលោក។ បន្ថែមពីនេះទៀត ការអប់រំផ្តល់ឱ្យយើងនូវការយល់ដឹងយ៉ាងជ្រាលជ្រៅថា យើងត្រូវបានភ្ជាប់ជាមួយគ្នាក្នុងនាមជាពលរដ្ឋនៃសហគមន៍ពិភពលោក ហើយថាបញ្ហាប្រឈមរបស់យើងត្រូវបានផ្សារភ្ជាប់គ្នាទៅវិញទៅមក (Ban Ki-moon, UN Secretary-General)។ មិនតែប៉ុណ្ណោះ ឥរិយាបថការងារអាចប៉ះពាល់ដល់ការបំពេញការងាររបស់បុគ្គលិកទាំងអស់នៅក្នុងអង្គភាពដោយផ្ទាល់ និងដោយប្រយោល។ Bateman និង Organ (១៩៦៣) បានបង្កើតកម្រងសំណួរដើម្បីវាស់ស្ទង់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព និងបានលើកឡើងថា ចំណុចវិជ្ជមាននៃឥរិយាបថរបស់បុគ្គលិក ចំពោះអង្គភាពត្រូវបានគេចាត់ទុកថាជារឿងដ៏មានសារៈសំខាន់ខ្លាំងណាស់ក្នុងការស្វែងយល់ពីតថភាពជាក់ស្តែងផ្អែកលើការយល់ឃើញរបស់បុគ្គលិក។ ឥរិយាបថបុគ្គលិកក្នុងអង្គភាពក៏ជះឥទ្ធិពលទាំងបុគ្គលផ្ទាល់ និងអង្គភាពទាំងមូលចំពោះការពេញចិត្តនឹង

ការងារ និងផលិតភាព។ ទន្ទឹមនឹងគ្នានេះដែរ គុណភាពនៃជីវិតការងារឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងបុគ្គលិក និងបរិយាកាសអង្គភាព ដែលលើកទឹកចិត្តដល់ការបំពេញការងារប្រចាំថ្ងៃ និងការអភិវឌ្ឍរបស់ស្ថាប័នដែលនឹងនាំឱ្យមានការពេញចិត្តរបស់បុគ្គលិកផងដែរ (Walton, ១៩៧៣)។

ការសិក្សាលើការគ្រប់គ្រង និងការអភិវឌ្ឍការអប់រំនឹងបង្កើនគុណភាពនៃជីវិតការងារ និងបរិយាកាសរៀបចំការងារដែលល្អនឹងបង្កើនសមត្ថភាព និងផលិតភាពសម្រាប់អង្គភាព ឬស្ថាប័នអប់រំស្របតាមគំនិតរបស់ Katz និង Kahn (១៩៧៨) ដែលបានបញ្ជាក់ថា ប្រសិទ្ធភាពការងារ គឺជាកូនសោរនៃការបំពេញការងាររបស់ពួកគេនៅក្នុងអង្គភាព។ ទោះជាយ៉ាងណាក្នុងគោលបំណងដើម្បីឱ្យមានភាពជិតស្និតរវាងការបំពេញការងារ និងបរិយាកាសក្នុងអង្គភាពគ្រប់ស្ថាប័នត្រូវតែមានអ្នកត្រួតពិនិត្យជាក់លាក់លើការពិនិត្យតាមដាន វង្វាយតម្លៃចំពោះការដាក់ចេញនូវសំពាធការងារ ភាពជឿជាក់ ការលើកទឹកចិត្ត ព្រមទាំងស្វ័យវង្វាយតម្លៃផងដែរ។ គួរកត់សម្គាល់ថាភាពជាប់ទាក់ទងនឹងពេលវេលា (Campbell, Dunnette, Lawler & Weick, ឆ្នាំ១៩៧០)។ ដោយយោងទៅតាមការយល់ឃើញនេះ គ្រូបង្រៀនទាំងអស់ត្រូវបានគាំទ្រដើម្បីបង្ហាញឥរិយាបថប្រកបដោយប្រសិទ្ធភាព ការចូលរួម និងឯករាជ្យបន្ថែមទៀតនៃប្រព័ន្ធលើកទឹកចិត្តផ្លូវការសម្រាប់គោលបំណងរបស់អង្គភាព។ ត្រង់ចំណុចនេះហើយ ឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាព គឺជាគោលគំនិតគួរឱ្យចាប់អារម្មណ៍បំផុតហើយស្ថានភាពនេះគឺពិតជាសាកសមសម្រាប់អង្គភាពសាលារៀន (Celep et al., ឆ្នាំ២០០៥; Kocel, ឆ្នាំ២០១៣ & Ersahan, ឆ្នាំ២០១១)។

សរុបមក ឥរិយាបថភាពភាពជាពលរដ្ឋសកលក្នុងអង្គភាព ជាគំនិតសំខាន់មួយពីព្រោះវាជាឥទ្ធិពលលើឥរិយាបទរបស់សមាជិក ឬបុគ្គលិកក្នុងអង្គភាពក្រោមបង្គាប់។ វាត្រូវបានផ្សារភ្ជាប់ជាមួយនឹងវិធានការលទ្ធផលដូចជាការពេញចិត្តការងារ និងផលិតភាព។ វាដើរតួនាទីជាគោលការណ៍ណែនាំសម្រាប់ដោះស្រាយជាមួយមនុស្សនិងមានឥទ្ធិពលយ៉ាងសំខាន់លើការលើកទឹកចិត្តពួកគាត់ និងផលិតភាពរបស់បុគ្គលក៏ដូចជាក្រុមការងារ។ ឥរិយាបថការងារល្អនាំមកនូវផ្លែផ្កាសម្រាប់អង្គភាព។ អ្នកគ្រប់គ្រងចាត់វិធានការលើមធ្យោបាយ

និងបែបបទបំពេញការងារជាប្រចាំថ្ងៃរបស់បុគ្គលិក ដែលមានន័យថាពួកគេចាត់ទុកលើការធ្វើការងាបានល្អជាទ្រព្យយ៉ាងសកម្មរបស់អង្គភាព។ ចំពោះសំណុំនៃគុណតម្លៃយ៉ាងជាក់លាក់ក្នុងការបំពេញការងាររបស់បុគ្គលិកក្នុងអង្គភាពមួយដែលអាចត្រូវបានបង្កើតចេញទាក់ទងជាមួយសមាជិក និងបរិស្ថានរបស់ជុំវិញអង្គភាព។ វាត្រូវបានឆ្លុះបញ្ចាំងពីការយល់ឃើញរបស់មនុស្សម្នាក់ៗ ចំពោះអង្គភាពដែលវាជាការទទួលខុសត្រូវរបស់បុគ្គលិកទាំងអស់។ កត្តាដែលត្រូវបានយល់ឃើញដោយបុគ្គលិក អំពីអង្គភាពរបស់ពួកគេដែលបម្រើជាកម្លាំងដ៏សំខាន់ក្នុងការរួមចំណែកលើកកម្ពស់ឥរិយាបថរបស់ពួកគេ និងការងាររបស់ពួកគេ។ កត្តាទាំងនេះអាចរួមបញ្ចូល ទម្រង់រចនាសម្ព័ន្ធរបស់អង្គភាព ការអនុវត្ត និងការវាយតម្លៃស្តង់ដារភាពជាអ្នកដឹកនាំ បញ្ហាប្រឈមការបង្កើតថ្មី តម្លៃអង្គភាព និងទម្លាប់ធ្វើការងារជាដើម។

## ១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ

កម្ពុជាបានចាប់ផ្តើមកសាងរចនាសម្ព័ន្ធ និងស្ថាប័ននយោបាយ សង្គម និងសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីបានបញ្ចប់ជម្លោះផ្ទៃក្នុង។ ទន្ទឹមនឹងការសម្រេចបានលទ្ធផលធំធេង ក្នុងការដោះស្រាយបញ្ហាប្រឈមធំ ដោយប្រើប្រាស់រយៈពេលខ្លី កម្ពុជាមានលទ្ធភាពបង្កើត និងរៀបចំប្រព័ន្ធអប់រំជាតិឡើងវិញដោយបានដាក់ចេញនូវគោលនយោបាយយ៉ាងច្បាស់លាស់ យន្តការអភិបាលកិច្ចដែលមានដំណើរការ និងគ្រឹះស្ថានសិក្សាជាច្រើននៅទូទាំងប្រទេស។ ក្រសួង តែងតែតាមដានត្រួតពិនិត្យ នៅតាមអង្គភាពនីមួយៗ នៅទូទាំងប្រទេស ដើម្បីសម្របសម្រួលលើដំណើរការសាលារៀនទាំងនោះ ក្នុងចេតនាជួយពង្រឹង និងដោះស្រាយបញ្ហាផ្សេងៗដែលតែងតែកើតមាននៅក្នុងអង្គភាពទាំងនោះ។ តែទោះបីជាក្រសួង ឬស្ថាប័នពាក់ព័ន្ធដទៃទៀតយកចិត្តទុកដាក់ទៅលើអង្គភាពនីមួយៗយ៉ាងណា ក៏គេនៅតែសង្កេតឃើញថាអង្គភាពទាំងនោះ នៅតែមានបញ្ហាតិច និងច្រើនជៀសមិនផុតឡើយ។ ដោយបញ្ហាប្រឈមទាំងនោះមានជាអាទិ៍ ការដោះស្រាយបញ្ហានៅតាមសាលារៀនមានឥរិយាបថការងារក្នុងអង្គភាព ទម្លាប់បំពេញការងារក្នុងសាលារៀន ការគ្រប់គ្រងតាមសាលារៀន និងគន្លងអាជីពវង្វាយតម្លៃលទ្ធផល ប្រចាំឆ្នាំរបស់គ្រូបង្រៀន និងនាយកសាលារៀន ផ្អែកលើកិច្ចព្រមព្រៀង និង

យោបល់របស់អ្នកទទួលសេវាដើម្បីអាចកំណត់ មុខសញ្ញាគ្រូ និងនាយក ឈានមុខគម្រូ និងឆ្នើម វាយតម្លៃលទ្ធផលពាក់កណ្តាលឆ្នាំ និងចុងឆ្នាំរបស់គ្រូបង្រៀនម្នាក់ៗ និងគណៈនាយក ដោយផ្អែកលើ៖ (ក) ផលសម្រេចកិច្ចព្រមព្រៀង (ខ) យោបល់សិស្ស (គ) យោបល់មាតាបិតាសិស្ស និង(ឃ)យោបល់របស់អ្នកធ្វើការជាមួយគ្នា។ ស្វ័យភាព ការលើកទឹកចិត្តគ្រូជាដើម (Hang Choun Naron, ឆ្នាំ២០២០)។ ការសិក្សាពីឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព ត្រូវបានអ្នកសិក្សា និងអ្នកប្រាជ្ញនៅប្រទេសជាច្រើនក្នុងពិភពលោកធ្វើការស្រាវជ្រាវ និងធ្វើបច្ចុប្បន្នីយកម្មជិតបួនទស្សវត្សរ៍មកហើយ ប៉ុន្តែតាមការស្រាវជ្រាវ និងចំណេះដឹងរបស់អ្នកស្រាវជ្រាវ ពុំទាន់ឃើញមានការសិក្សាពីឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀននៅកម្រិតសាលារៀនក្នុងប្រទេសកម្ពុជានៅឡើយ។ ការសិក្សានេះ នឹងបង្ហាញបានពីកម្រិតឥរិយាបថផ្ទាល់របស់គ្រូបង្រៀន និងស្នើជាគោលគំនិតសម្រាប់ការលើកកម្ពស់ឥរិយាបថការងាររបស់គ្រូបង្រៀនក្នុងអង្គភាពនៅកម្រិតសាលារៀនឱ្យស្របទៅនឹងស្តង់ដារសកលលោក។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវ មានដូចខាងក្រោម៖

១-សិក្សាពីទស្សនៈរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ លើឥរិយាបថក្នុងអង្គភាពរបស់ពួកគេ។

២-វាស់ស្ទង់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព របស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុង រាជធានីភ្នំពេញ ដោយផ្អែកតាមភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍ការបង្រៀន។

## ១.៤- សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅគោលបំណងខាងលើ អ្នកស្រាវជ្រាវបានកំណត់សំណួរស្រាវជ្រាវដូចខាងក្រោម៖

១- តើទស្សនៈរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ លើឥរិយាបថភាពជាពលរដ្ឋសកលស្ថិតក្នុងកម្រិតណា ដោយផ្អែកលើទ្រឹស្តីរបស់លោកប៊េតមេន និងអូហ្គិន Bateman and Organ(១៩៨៣)៖

- ឧត្តមគតិ
- អត្តទត្ថបុគ្គល
- និយ័តភាពការងារ
- ភាពបម្រុងប្រយ័ត្ន
- មនុស្សធម៌ការងារ

២- តើមានភាពដូចគ្នា ឬខុសគ្នាដែរឬទេ ចំពោះទស្សនៈរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ទៅលើឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព ដោយផ្អែកតាមភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍ការបង្រៀន?

## ១.៥- សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីប្រធានបទ " **ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ** " ពិតជាមានសារៈសំខាន់ណាស់ វាធ្វើឲ្យយល់ដឹងពីទស្សនៈរបស់គ្រូបង្រៀននៅកម្រិតវិទ្យាល័យនៃសាលារៀនរដ្ឋក្នុងរាជធានីភ្នំពេញ លើឥរិយាបថភាពរបស់គ្រូបង្រៀន ដែលអាចជះឥទ្ធិពលដល់ការបំពេញការងាររបស់គាត់ស្ថិតក្នុងកម្រិតណាមួយ។ លើសពីនេះ យើងអាចធ្វើជាសូចនាករវាស់វែងដើម្បីកែលម្អអង្គភាព និងបង្កើនប្រសិទ្ធភាពការងារឲ្យកាន់តែល្អប្រសើរ។ ម៉្យាងទៀត គឺដឹងកាន់តែច្បាស់ពីភារកិច្ចរបស់ខ្លួនផងដែរ ជាហេតុធ្វើឲ្យងាយស្រួលក្នុងការជួយអភិវឌ្ឍសាលារៀន។ មួយវិញទៀត វាជួយដល់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យបានមើលឃើញពី តថភាពជាក់ស្តែងក្នុងពេលបំពេញភារៈកិច្ចថា តើមានផលជះអ្វីខ្លះ ទៅដល់ពួកគាត់នៅតាមអង្គភាពនីមួយៗ ដើម្បីងាយស្រួលក្នុងការជួយដោះស្រាយស្ថានភាពផ្សេងៗ ក៏ដូចជាងាយស្រួលក្នុងការអភិវឌ្ឍ វិស័យអប់រំផងដែរ។ មិនត្រឹមតែប៉ុណ្ណោះប្រធានបទនេះ អាចសម្រាប់ទុកជាឯកសារជំនួយស្មារតីដល់អ្នកសិក្សារៀនសូត្រ និងការសិក្សាស្រាវជ្រាវផ្សេងៗផងដែរ។

ជាពិសេសការស្រាវជ្រាវនេះ មានប្រយោជន៍សម្រាប់ការយល់ដឹងអំពីបុគ្គលិកលក្ខណៈរបស់គ្រូបង្រៀនក្នុងអង្គភាពដូចជា ការចេះជួយគ្នា និយ័តភាពការងារ ការប្រាស្រ័យទាក់ទង និងប្រសិទ្ធភាពការងារជាដើម។ នេះជាការបង្ហាញឥរិយាបថរបស់សមាជិកចំពោះអង្គភាពតាមគោលដៅភាពជាពលរដ្ឋសកល។ អង្គភាពមួយមានបរិយាកាសទាក់ទាញ និងរក្សាមនុស្សដែលសមស្របនឹងស្ថានភាពការងារ ជាហេតុនាំឲ្យការបំពេញការងារបានស្ថិតស្ថេរ និងល្អប្រសើរមួយកម្រិតថែមទៀត។ លទ្ធផលការសិក្សានេះ នឹងជួយដល់ការបំពេញការងារ ក្នុងអង្គភាពបានប្រសើរជាងមុន ដើម្បីនាំមកនូវការផ្លាស់ប្តូរគំរូឥរិយាបថរបស់មនុស្សនៅក្នុងអង្គភាពឱ្យដើរតាមស្តង់ដារសកល ការផ្លាស់ប្តូរបុគ្គលិកលក្ខណៈមិនសមស្របរបស់បុគ្គលិក និងការដឹកនាំគ្រប់គ្រង ឈានឆ្ពោះទៅរួមចំណែកក្នុងការបង្កើតបរិយាកាសសាលារៀនដែលមានសុភាពល្អ និងមានឥទ្ធិពលលើភាពជោគជ័យរបស់សិស្សក្នុងការសិក្សា។ ប្រសិនបើការផ្លាស់ប្តូរស្ថានភាពកន្លែងការងារមិនស៊ីគ្នានឹងប្រព័ន្ធនៃការយល់ឃើញរបស់បុគ្គលិកអាចមានការតស៊ូមតិខ្លះពីបុគ្គលិកនៅក្នុងអង្គភាពនោះ។

## ១.៦- វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវ ត្រូវបានកំណត់ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ដូចខាងក្រោម៖

### ១.៦.១- ផ្នែកខ្លឹមសារ

ខ្លឹមសារ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ គឺកម្រងសំណួរ មាន ៥ ចំណុចគោល និង៤០ ចំណុចរង ដោយផ្អែកលើទ្រឹស្តីរបស់ប៊េតមេននិងអូហ្គិន Bateman & Organ ( ១៩៨៣ ) ដូចខាងក្រោម៖

- ឧត្តមគតិ មាន៥ចំណុច
- អត្តទត្ថបុគ្គល មាន៥ចំណុច
- និយ័តភាពការងារ មាន៥ចំណុច
- ភាពបម្រុងប្រយ័ត្ន មាន៥ចំណុច
- មនុស្សធម៌ការងារ មាន៥ចំណុច

### ១.៦.២- ប្រជាជន និងភាគសំណាក

**ក- ប្រជាជន** គឺសំដៅដល់គ្រូបង្រៀនកម្រិតវិទ្យាល័យ (នៅវិទ្យាល័យដែលមានកម្រិតពីទី៧ ដល់ទី១២) សរុបចំនួន (EMIS) ក្នុងរាជធានីភ្នំពេញ របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំសិក្សា ២០២១-២០២២។

**ខ- ភាគសំណាក** ក្នុងការសិក្សាស្រាវជ្រាវនេះ គឺត្រូវបានធ្វើឡើងដោយកំណត់យកតាមសាលាវិទ្យាល័យចំនួន ០៦ ចំណោមវិទ្យាល័យទាំង និងខណ្ឌទាំង ក្នុងរាជធានីភ្នំពេញ។

### ១.៦.៣- អថេរនៃការសិក្សា

ការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់លើបួនចំណុចជាចម្បងគឺ តាមភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍ការបង្រៀន ជាអថេរឯករាជ្យនិងឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព ដែលមានប្រាំចំណុចជាអថេរមិនឯករាជ្យ ។

### ១.៦.៤- រយៈពេលនៃការសិក្សា

ការសិក្សាស្រាវជ្រាវនេះ នឹងប្រើរយៈពេល ៨ ខែ

## ១.៧- និយមន័យពាក្យគន្លឹះនៃការស្រាវជ្រាវ

១- ឥរិយាបថ នៅទីនេះសំដៅទៅលើសកម្មភាពទាំងអស់ដែលដឹកនាំដោយសារពាង្គកាយឆ្ពោះទៅរកភាពខាងក្រៅ ក្នុងន័យផ្លាស់ប្តូរលក្ខខណ្ឌនៅក្នុងខ្លួនបុគ្គល ឬដើម្បីផ្លាស់ប្តូរស្ថានភាពរបស់ពួកគេទៅនឹងបរិស្ថានជុំវិញ ហើយវាបង្ហាញឱ្យដឹងពីសកម្មភាព ការបង្ហាញចេញ ការប្រាស្រ័យទាក់ទងទៅចំពោះគ្នានឹងគ្នាក្នុងកន្លែងមួយ (Routledge, ២០១៣)។

២- អង្គភាព នៅទីនេះសំដៅដល់គុណភាពនៃបរិស្ថានការងារដែលត្រូវបានផ្សារភ្ជាប់ជាមួយនឹងមនុស្សតាមរយៈចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងជាច្រើនអំពីរបៀបរៀបចំ និងគ្រប់គ្រងអង្គភាព Simon (១៩៧៦)។

៣- កម្រិតវិទ្យាល័យ នៅទីនេះសំដៅដល់គ្រឹះស្ថានសិក្សាចំណេះទូទៅរដ្ឋចាប់ពីថ្នាក់ទី៧ ដល់ទី១២។

៤- គ្រូបង្រៀន នៅទីនេះសំដៅដល់គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ ជាមន្ត្រីរាជការដែលបង្រៀនសាលារដ្ឋក្នុងរាជធានីភ្នំពេញ។

៥- ពលរដ្ឋសកល គឺដំដៅលើពលរដ្ឋដែលជាកម្មសិទ្ធិរបស់សហគមន៍ដ៏ធំទូលាយ និងជារបស់មនុស្សជាតិទូទៅ។ វាសង្កត់ធ្ងន់ទៅលើការអាស្រ័យគ្នាទៅវិញទៅមកទាំងផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ក៏ដូចជាការផ្សារភ្ជាប់គ្នាទៅវិញទៅមករវាងមូលដ្ឋាន ជាតិ និងសកលលោក (UNESCO, ២០១៤, Global citizenship education: Preparing learners for the challenges of the 21st century)។

៦- ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព គឺត្រូវបានកំណត់ថាជាឥរិយាបថឆន្ទានុសិទ្ធិដែលសំដៅលើបុគ្គលទាំងមូល ហើយប្រភេទឥរិយាបថនេះ លើសពីតួនាទីជាក់ស្តែងដែលជាកាតព្វកិច្ចមានស្រាប់ ប៉ុន្តែផ្តល់ត្រឡប់វិញនូវអត្ថប្រយោជន៍ដល់អង្គភាពយ៉ាងច្រើនលើសលប់ (Organ, ១៩៨៨)។

## ១.៨- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

និក្ខេបបទនេះចែកចេញជា ៥ជំពូកដូចខាងក្រោម៖

**ជំពូកទី១ ៖** បង្ហាញពីសេចក្តីផ្តើម ដែលចែកចេញជាប្រាំបីចំណុច ១- លំនាំបញ្ហានៃការស្រាវជ្រាវ ២- ចំណោទបញ្ហានៃការស្រាវជ្រាវ ៣- គោលបំណងនៃការស្រាវជ្រាវ ៤- សំណួរស្រាវជ្រាវ ៥- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ៦- សារៈសំខាន់នៃការស្រាវជ្រាវ ៧- និយមន័យ និងពាក្យគន្លឹះនៃការស្រាវជ្រាវ ៨- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២ ៖** ជាផ្នែករំលឹកទ្រឹស្តី គឺជាការបង្ហាញ និងការពារអំណះអំណាងរបស់វត្ថុបំណងនៃការសរសេរនិក្ខេបបទ ដោយលើកយកទ្រឹស្តីរបស់អ្នកប្រាជ្ញ លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗ ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាព និងការប្រកបការងាររបស់បុគ្គលិកសិក្សា (គ្រូបង្រៀនកម្រិតវិទ្យាល័យ)។

**ជំពូកទី៣ ៖** វិធីសាស្ត្រនៃការស្រាវជ្រាវ ជំពូកនេះនឹងលើកឡើងពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងគម្រោងនៃការវិភាគ ដោយកំណត់ទៅលើអថេរឯករាជ្យ និងអថេរមិនឯករាជ្យ សម្រាប់ការសិក្សា បង្ហាញពីការកំណត់ពេលវេលា និងទីកន្លែងគោលដៅដែលត្រូវសិក្សាស្រាវជ្រាវ។ ការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យវិភាគសំណាក ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើរូបមន្តសម្រាប់គណនា និងជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ។

**ជំពូកទី៤ ៖** លទ្ធផល និងការពិភាក្សា ត្រូវលើកឡើងពីលក្ខណៈជាក់ស្តែងដែលបានធ្វើការសិក្សាស្រាវជ្រាវហើយចំណុចនីមួយៗដែលត្រូវលើកឡើង គឺត្រូវឱ្យចូលទៅក្នុងចំណុចដែលចោទសួរទាំងអស់ក្នុងចំណោទបញ្ហា។ ការពិភាក្សាត្រូវពិភាក្សាយ៉ាងលម្អិតទៅលើកម្រងសំណួរសម្រាប់យកមកវិភាគ និងប្រមូលទិន្នន័យ ហើយនឹងធ្វើការបកស្រាយលើទិន្នន័យដែលប្រមូលបានជាក់ស្តែង ក្នុងគោលបំណងវិភាគឱ្យឃើញចំណុចខ្វះខាត បញ្ហាប្រឈម ដើម្បីធ្វើការកែលម្អ។

**ជំពូកទី៥ ៖** ជាសេចក្តីសន្និដ្ឋាន និងការផ្តល់សំណូមពរ ធ្វើការសន្និដ្ឋានលើគ្រប់ចំណុចដែលបានវិភាគ និងផ្តល់ជាយោបល់ ជាសំណូមពរទៅលើចំណុចដែលត្រូវកែលម្អ។

# ជំពូកទី២
# រំលឹកទ្រឹស្តី និងការស្រាវជ្រាវដែលពាក់ព័ន្ធ

# ជំពូក២

# រំលឹកទ្រឹស្តី និងការស្រាវជ្រាវដែលពាក់ព័ន្ធ

## ២.១- បញ្ញត្តិ និងទ្រឹស្តីពាក់ព័ន្ធនឹងពលរដ្ឋសកលនិងឥរិយាបថភាពជាពលរដ្ឋសកល

ផ្នែកនេះ បង្ហាញពីបញ្ញត្តិ និងទ្រឹស្តីដែលទាក់ទងនឹងក្របខណ្ឌគំនិតដើម្បីគាំទ្រការស្រាវជ្រាវ។ ចំណេះដឹងដែលទទួលបានយ៉ាងទូលំទូលាយ បង្កើតបានជាប្រវត្តិសាស្ត្រមួយសម្រាប់ការវិភាគ និងការបកស្រាយជាបន្តបន្ទាប់នៃទិន្នន័យដែលប្រមូលបាន សម្រាប់ការសិក្សាស្រាវជ្រាវបន្ទាប់ទៀត។ ដោយផ្អែកលើការពិនិត្យឡើងវិញនៃទ្រឹស្តីដែលពាក់ព័ន្ធទៅនឹងជំពូកនេះ មានប្រធានបទជាច្រើនត្រូវបានពិពណ៌នា បកស្រាយ និងលើកមកបង្ហាញ។ និយមន័យការអប់រំពលរដ្ឋសកលនិងឥរិយាបថភាពជាពលរដ្ឋសកល រួមបញ្ចូលជាមួយនឹងគោលដៅ ក៏ដូចជាសារៈប្រយោជន៍ចំពោះអ្នកសិក្សា ត្រូវបានបង្ហាញប្រាប់ដើម្បីជាគំរូទ្រឹស្តីនៃលក្ខណៈការអនុវត្តឥរិយាបថភាពជាពលរដ្ឋសកល។ ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព ត្រូវបានសិក្សាស្រាវជ្រាវនៅតាមបណ្តាប្រទេសជាច្រើននៅក្នុងសកលលោក។ លើសពីនេះទៅទៀតការវាស់ស្ទង់ ការយល់ឃើញនៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពត្រូវបានដោះស្រាយ និងអភិវឌ្ឍន៍ ហើយការសិក្សាស្រាវជ្រាវពីមុនស្តីពីឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាពត្រូវបានពិភាក្សាជាចម្បង។ កម្រិតទ្រឹស្តីមួយចំនួនលើការស្រាវជ្រាវឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព នៅក្នុងទីភ្នាក់ងារយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសប៉ូលីសក៏បានលើកយកមកពិភាក្សា។ ការពិភាក្សាខ្លីនៃក្របខណ្ឌគំនិតដែលប្រើក្នុងការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធទាំងនេះ ត្រូវបានបង្ហាញនៅក្នុងផ្នែកចុងក្រោយ។ ការដោះស្រាយផ្នែកសំខាន់ៗទាំងនេះនៅក្នុងការស្រាវជ្រាវដែលពាក់ព័ន្ធទាំងឡាយផ្តល់ទាំងមូលដ្ឋានគ្រឹះ និងទ្រឹស្តីសម្រាប់ការសិក្សា។

### ២.១.១- អត្ថន័យឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព

ឥរិយាបថរបស់បុគ្គលិកដែលមិនត្រូវបានទាមទារ ជាផ្នែកមួយនៃការពិពណ៌នាការងារ ប៉ុន្តែត្រូវបានចូលរួមដើម្បីសម្រេចបាននូវគោលបំណងពាក់ព័ន្ធរបស់អង្គភាព ត្រូវបានសិក្សាអស់រយៈពេលជាយូរមកហើយ។ និយមន័យមួយចំនួនត្រូវបានស្នើឡើងដោយអ្នកប្រាជ្ញផ្សេងៗ។

**តារាងទី២.១.ចំណុចលេចធ្លោរមួយចំនួនត្រូវបានលើកឡើងក្នុងតារាងខាងក្រោម៖**

| | |
|---|---|
| បាណាត (Barnard ឆ្នាំ១៩៣៨) | ឆន្ទៈរបស់មនុស្សក្នុងការរួមចំណែកកិច្ចខំប្រឹងប្រែងក្នុងប្រព័ន្ធសហការ |
| ខេត(Katz ឆ្នាំ១៩៦៤) | ឥរិយាបថប្រកបដោយភាពច្នៃប្រឌិត និងដោយឯកឯង |
| ប៊េតមេន និងអូហ្គិន (Bateman and Organ ឆ្នាំ១៩៨៣) | ឥរិយាបថប្រកបដោយការសម្រេចចិត្ត មិនត្រូវបានផ្ដល់រង្វាន់យ៉ាងច្បាស់លាស់ដោយប្រព័ន្ធរង្វាន់ផ្លូវការ និងដែលលើកកម្ពស់ដំណើរការរបស់អង្គភាពប្រកបដោយប្រសិទ្ធភាព |
| ក្រាហាម (Graham ឆ្នាំ ១៩៩១) | រាល់ឥរិយាបថវិជ្ជមានទាំងអស់សុទ្ធតែពាក់ព័ន្ធនឹងសហគមន៍ |

បាណាត (Barnard ឆ្នាំ១៩៨៣) បានយល់ឃើញពីឥរិយាបថទាំងនោះថា "ឆន្ទៈមនុស្សក្នុងការរួមចំណែកកិច្ចខិតខំប្រឹងប្រែងក្នុងប្រព័ន្ធសហប្រតិបត្តិការ" (ទំព័រ.៨៣)។ ខេត (Katz ឆ្នាំ១៩៦៤) បានកំណត់អត្តសញ្ញាណពួកគេថាជាឥរិយាបថច្នៃប្រឌិត និងឥរិយាបថភ្លាមៗ។ គាត់ក៏បានកំណត់សម្គាល់ផងដែរថា ការប្រព្រឹត្តនេះមិនមែនជាផ្នែកនៃភារកិច្ចការងារដែលត្រូវការនោះទេ ប៉ុន្តែទោះជាយ៉ាងណាក៏គួរឱ្យចង់បានសម្រាប់អង្គភាពទាំងមូល ឧទាហរណ៍ គំនិតផ្តួចផ្តើមបុគ្គល ឬដោយស្ម័គ្រចិត្តទទួលយកការទទួលខុសត្រូវបន្ថែម។ ផ្ទុយទៅវិញ ការអនុវត្តតួនាទីដែលអាចទុកចិត្តបាន សំដៅលើការអនុវត្តដោយស្មោះត្រង់នៃភារកិច្ច

ទាក់ទងនឹងការងារ ឧទាហរណ៍ ការប្រកាន់ខ្ជាប់នូវច្បាប់ និងបទប្បញ្ញត្តិរបស់ស្ថាប័ន ដូចជាការមកដល់ការិយាល័យទាន់ពេលវេលា មិនខ្ជះខ្ជាយពេលវេលា និងការគោរពច្បាប់។

អូហ្គិន និងមិត្តរួមការងារគាត់ (Organ, Smith, and Near, ឆ្នាំ១៩៨៣) បានបង្កើតពាក្យ "ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព-Organizational Citizenship Behavior" ឬហៅកាត់ថា OCB សំដៅទៅលើឥរិយាបថទាំងនេះ។ អូហ្គិន (Organ ឆ្នាំ១៩៨៨) បានកំណត់ OCB ថាជា "ឥរិយាបថដែលមានលក្ខណៈឆន្ទានុសិទ្ធិ មិនត្រូវបានទទួលស្គាល់ដោយផ្ទាល់ ឬច្បាស់លាស់ដោយប្រព័ន្ធរង្វាន់ផ្លូវការ ហើយថាជួយលើកកម្ពស់ដំណើរការប្រកបការងារដោយប្រសិទ្ធភាពសម្រាប់អង្គភាព" (ទំព័រទី៤)។ និយមន័យនេះមាន៣ផ្នែក។ ផ្នែកទី១និយាយថា ឥរិយាបថគឺឆន្ទានុសិទ្ធិហើយមិនត្រូវបានទាមទារជាផ្នែកនៃការងារនោះទេ។ ផ្នែកទី២បញ្ជាក់ថាប្រព័ន្ធរង្វាន់ផ្លូវការ មិនទទួលស្គាល់ឥរិយាបថនេះទេ ទោះបីជានេះមិនមានន័យថា OCB មិនដែលផ្តល់រង្វាន់នៅក្នុងអង្គភាពក្តី។ ជាការពិតទៅ រង្វាន់មិនត្រូវបានជានាទេ ហើយទំនាក់ទំនងរវាង OCB និងរង្វាន់គឺដោយប្រយោល (Organ ឆ្នាំ ១៩៩៧)។ ផ្នែកទី៣ ពន្យល់ថា OCB ត្រូវបានផ្សារភ្ជាប់ជាមួយនឹងដំណើរការប្រកបដោយប្រសិទ្ធភាពនៃអង្គភាពមួយ។ ដូចនេះ OCB ប្រហែលជាមិនផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់នរណាម្នាក់ទេ ប៉ុន្តែវាអាចគាំទ្រដល់មិត្តរួមការងារ និងអង្គភាព(Smith, Organ, and Near, ឆ្នាំ១៩៨៣)។

អ្នកស្រាវជ្រាវដំបូងមួយចំនួនដូចជា បេតមេន និងអូហ្គិន (Bateman and Organ ឆ្នាំ ១៩៨៣) រួមជាមួយ លោកស្មីត បានកំណត់ថា OCB ខុសពីការអនុវត្តការងារក្នុងតួនាទី ប៉ុន្តែពាក់ព័ន្ធនឹងមុខងាររបស់អង្គភាព។ ទោះជាយ៉ាងណាក៏ដោយលោកក្រាហាម (Graham ឆ្នាំ១៩៩១) បានប្រកែកថា វាមានផលវិបាកដោយអចេតនា នៃការស្វែងរកភាពខុសគ្នានៃការផ្លាស់ប្តូរជាញឹកញាប់រវាងឥរិយាបថក្នុងតួនាទី និងតួនាទីបន្ថែម ព្រោះវាប្រែប្រួលលើមនុស្ស ការងារ និងអង្គភាពនានា។ បន្ថែមពីនេះទៀតក្រាហាម បានស្នើនិយមន័យមួយដែលរួមបញ្ចូលឥរិយាបថវិជ្ជមាន ទាក់ទងនឹងសហគមន៍។ ការយល់ឃើញកាន់តែទូលំទូលាយ

នេះ រួមមានឥរិយាបថក្នុងតួនាទី ឥរិយាបថបន្ថែមដែលពាក់ព័ន្ធក្នុងស្ថាប័ន ក៏ដូចជាមុខងារនយោបាយដូចជាការចូលរួមរបស់អង្គភាពជាដើម។

ដើម្បីពិពណ៌នាអំពីឥរិយាបថដែលខុសពីតួនាទីនិងកាតព្វកិច្ច ហើយដើរហួសពីតួនាទី ដែលហៅថាឥរិយាបថបន្ថែម (Extra-role behaviors) ដើម្បីរួមចំណែកដល់ការបំពេញការងាររបស់អង្គភាព(Bateman and Organ, ឆ្នាំ១៩៨៣; Smith, Organ and Near, ឆ្នាំ១៩៨៣)។ អូហ្គិន និងមិត្តរួមការងាររបស់គាត់ប្រើពាក្យ "ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព OCB" និងបានផ្តល់អត្ថន័យដូចខាងក្រោមៈ

> Individual behavior that is discretionary, not explicitly recognized by the formal system and that in the aggregate promotes the effective functioning of the organization. By discretionary, we mean that the behavior is not an enforceable requirement of the role or job description, that is, the clearly specifiable terms of the person 's employment contract with the organization; the behavior is rather a matter of personal choice, such that its omission is not generally understood as punishable. (ឥរិយាបថផ្ទាល់ខ្លួនរបស់បុគ្គល ហៅថាឆន្ទានុសិទ្ធិ មិនបានត្រូវទទួលស្គាល់យ៉ាងច្បាស់ដោយប្រព័ន្ធផ្លូវការ ប៉ុន្តែវាស្ថិតនៅក្នុងដំណើរការលើកកម្ពស់ការងារប្រកបដោយប្រសិទ្ធភាពសម្រាប់អង្គភាពទាំងមូល។ ដោយឆន្ទានុសិទ្ធិមានន័យថា ឥរិយាបថដែលមិនតម្រូវឱ្យអនុវត្តនៅក្នុងតួនាទីការងារ ដែលបានត្រូវបានបញ្ជាក់ច្បាស់នៅក្នុងកិច្ចកុងត្រាការងាររបស់អង្គភាពនោះទេ វាគ្រាន់តែជាឥរិយាបថដែលជាជម្រើសផ្ទាល់ខ្លួនរបស់បុគ្គល ទោះជាមិនធ្វើក៏មិនត្រូវទទួលការពិន័យណាមួយពីអង្គភាពនោះដែរ។) (Organ, ឆ្នាំ១៩៨៨ ទំព័រ.៤)

លោកក៏បានបញ្ជាក់ទៀតថា OCB ទាមទារថាវាមិនគួរត្រូវបានអនុវត្តដោយផ្ទាល់ ឬជាផ្លូវការ តែគួរផ្តល់ដោយការលើកទឹកចិត្ត ឬរង្វាន់ពីអង្គភាព។ ទោះជាយ៉ាងណាក៏ដោយ នេះមិនមែនមានន័យថា OCB ត្រូវតែកំណត់ចំពោះឥរិយាបថដែលមិនទទួលបានអ្វីសោះចំពោះបុគ្គលដែលបានធ្វើវានោះទេ។ វាអាចកំណត់ឥទ្ធិពលដែលបុគ្គលជះឥទ្ធិពលទៅលើអ្នកគ្រប់គ្រង ឬអ្នករួមការងារ។ ឥទ្ធិពលនោះអាចប៉ះពាល់ដល់អ្នកគ្រប់គ្រងក្នុងការគិតគូរអំពីដំណើរការវាយតម្លៃបុគ្គលិកដោយការដំឡើងប្រាក់ខែ ឬការដំឡើងឋានៈជាដើម។ ទាំងនេះសាកសមទៅនឹងដំណើរការនៅក្នុងអង្គភាពសាលារៀន ដែលប្រើប្រាស់សម្រាប់ជាការជម្រុញឱ្យបុគ្គលិកទាំងអស់ចូលរួមជួយឱ្យការរៀននិងបង្រៀនកាន់តែទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ថែមទៀត។

ចាប់តាំងពី ខេត បាននិយាយជាលើកដំបូងអំពីឥរិយាបថប្រកបដោយការច្នៃប្រឌិត និងការគាំទ្រ ហើយ អូហ្គិន និងមិត្តរួមការងារគាត់បានណែនាំពាក្យ OCB នោះ អ្នកស្រាវជ្រាវផ្សេងទៀតបានប្រើឈ្មោះផ្សេងៗគ្នាដើម្បីពណ៌នាជម្រើសដូចគ្នានៃឥរិយាបថរបស់បុគ្គលិក។ ម៉ារីណូវ៉ា ម៉ូន និងដឺនី (Marinova, Moon, and Van Dyne ឆ្នាំ២០១០) បានគិតថា OCB ជាឥរិយាបថបន្ថែមនៅកន្លែងធ្វើការ ដូចទៅនឹងដឺនី ខុមមីង និងផាក (Dyne, Cummings, nad Parks ឆ្នាំ១៩៩៥)។ លើសពីនេះ ឥរិយាបថទាំងនេះត្រូវបានគេហៅថា ឥរិយាបថរបស់អង្គភាព (Brief and Motowidlo, ឆ្នាំ១៩៨៦ ; George and Bettenhausen, ឆ្នាំ១៩៩០) ចំណែកភាពឯកានៃអង្គភាព(George and Brief, ឆ្នាំ១៩៩២; George and Jones, ឆ្នាំ១៩៩៧) និងការអនុវត្តបរិបទ (Borman and Motowidlo, ឆ្នាំ១៩៩៣)។ បន្ថែមពីនេះទៀតថា ឥរិយាបថទាំងនេះត្រូវបានគេហៅថា ឥរិយាបថគាំទ្រ ដូចនេះ ឥរិយាបថស្រដៀងទៅនឹងអ្វីដែលកំណត់ដោយបាណាត (Barnard ឆ្នាំ ១៩៨៣) និង ខេត (Katz ឆ្នាំ១៩៦៤) ត្រូវបានកំណត់អត្តសញ្ញាណក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ ទោះបីជាពួកគេត្រូវបានហៅដោយឈ្មោះផ្សេងគ្នាក៏ដោយ។

## ២.១.២- ការអប់រំភាពជាពលរដ្ឋសកល

ការកើនឡើងនូវពិភពលោកមួយដែលកាន់តែរួមគ្នា បាននាំទៅដល់ការបង្កើតបានភាពជាពលរដ្ឋសកលដ៏មានអត្ថន័យ និងមានសមាសធាតុចូលរួមជាច្រើនផងដែរ។ ទោះបីជាសញ្ញាណនៃភាពជាពលរដ្ឋសកលដែលមានវិសាលភាពហួសពីភាពជារដ្ឋឯករាជ្យមួយ មិនមែនជារឿងថ្មីក៏ដោយ ក៏ការផ្លាស់ប្តូរទាំងឡាយនៅក្នុងបរិបទសកល (ឧទាហរណ៍៖ ការបង្កើតអនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិ ការកើនឡើងនូវអង្គការអន្តរប្រទេស សាជីវកម្ម និងចលនាសង្គមស៊ីវិល និងការការអភិវឌ្ឍក្របខណ្ឌសិទ្ធិមនុស្សអន្តរជាតិ) មានឥទ្ធិពលយ៉ាងសំខាន់ទៅលើភាពជាពលរដ្ឋសកល។ ត្រូវមានការទទួលស្គាល់ថា មានការយល់ឃើញផ្សេងៗគ្នាទៅលើទស្សនៈស្តីពីភាពជាពលរដ្ឋសកល។

ភាពជាពលរដ្ឋសកលសំដៅទៅលើអារម្មណ៍ ដែលថាខ្លួនជាផ្នែកមួយនៃសហគមន៍ និងភាពជាមនុស្សជាតិទូទៅ និងទូលំទូលាយជាងមុន។ វាគូសបញ្ជាក់អំពីការអាស្រ័យគ្នាទៅវិញទៅមក និងការជាប់ពាក់ព័ន្ធគ្នាទៅមកផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ រវាងថ្នាក់មូលដ្ឋាន ជាតិ និងសកល។ ការអប់រំភាពជាពលរដ្ឋសកលរួមបញ្ចូលសមាសធាតុនៃទស្សនៈសំខាន់ៗចំនួនបី ដែលមានលក្ខណៈរួមចំពោះនិយមន័យ និងការបកស្រាយផ្សេងគ្នា។ សមាសធាតុនៃទស្សនៈសំខាន់នោះចេញមកអំពីការពិនិត្យមើលទៅលើការបោះពុម្ពទាំងឡាយ ក្របខណ្ឌទស្សន វិធីសាស្ត្រ និងកម្មវិធីសិក្សាអំពីការអប់រំភាពជាពលរដ្ឋសកល ក៏ដូចជាការប្រឹក្សាយោបល់ផ្នែកបច្ចេកទេស និងកិច្ចការនាពេលថ្មីៗនេះរបស់អង្គការយូណេស្កូទាក់ទងនឹងប្រធានបទនេះ។ សមាសធាតុជាទស្សនសំខាន់ៗទាំងនេះផ្អែកទៅលើ និងរួមបញ្ចូលទិដ្ឋភាពទាំងឡាយពីគ្រប់ទម្រង់ទាំងអស់នៃការសិក្សា៖ ចំណេះដឹង ចិត្តសង្គម និងឥរិយាបថ។ សមាសធាតុទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក និងត្រូវបានបង្ហាញខាងក្រោម ដែលមាសធាតុនីមួយៗចង្អុលបង្ហាញទម្រង់នៃការសិក្សា ដែលផ្តោតជាសំខាន់នៅក្នុងដំណើរការនៃការសិក្សា។ សមាសធាតុទស្សនៈសំខាន់ៗនៃការអប់រំភាពជាពលរដ្ឋសកលមានចំនួនបីមានដូចជា ចំណេះដឹង ចិត្តសង្គម និងឥរិយាបថ(ការអប់រំភាពជាពលរដ្ឋសកល យូណេស្កូ ២០១៥)។

១)- ចំណេះដឹង៖ ដើម្បីទទួលបានចំណេះដឹង ការយល់ដឹង និងការត្រិះរិះពិចារណាអំពីបញ្ហានៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងសកល និងទំនាក់ទំនំនងក៏ដូចជាការអាស្រ័យគ្នាទៅវិញទៅមក រវាងប្រទេស និងប្រជាជនផ្សេងៗគ្នា។

២)- ចិត្តសង្គម៖ ដើម្បីទទួលបាននូវអារម្មណ៍ថាជាផ្នែកមួយនៃមនុស្សជាតិទូទៅ ដោយចែករំលែកនូវតម្លៃការទទួលខុសត្រូវ សេចក្តីអាណិតអាសូរ សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នា និងពិពិធភាព។

៣)- ឥរិយាបថ៖ ធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ នៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងសកល ដើម្បីទទួលបាននូវពិភពលោក ដែលប្រកបដោយសន្តិភាព និងនិរន្តរភាពជាងមុន។

### ២.១.៣- គោលបំណងការអប់រំភាពជាពលរដ្ឋសកល

តាមរយៈសៀវភៅស្ដីអំពីការអប់រំភាពជាពលរដ្ឋសកលរបស់អង្គការយូណេស្កូ ឆ្នាំ២០១៥ បានបង្ហាញអំពីគោលបំណងដែលចង់ឱ្យអ្នកសិក្សាសម្រេចបាន តាមរយៈការអប់រំភាពជាពលរដ្ឋសកលរួមមាន៖

១)- អភិវឌ្ឍនូវការយល់ដឹងមួយស្ដីអំពីរចនាសម្ព័ន្ធអភិបាលកិច្ចសកល សិទ្ធិនិងការទទួលខុសត្រូវ បញ្ហាសកល និងទំនាក់ទំនងរវាងប្រព័ន្ធនិងដំណើរការនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល។

២)- ទទួលស្គាល់ និងលើកសរសើរភាពខុសគ្នា និងពហុអត្តសញ្ញាណ ដូចជាវប្បធម៌ ភាសា សាសនា ភេទ និងមនុស្សជាតិទូទៅ និងអភិវឌ្ឍជំនាញសម្រាប់ការរស់នៅ នៅក្នុងពិភពលោកមួយដែលកាន់តែមានពិពិធភាព។

៣)- អភិវឌ្ឍ និងអនុវត្តជំនាញក្នុងការត្រិះរិះពិចារណា ដើម្បីក្លាយទៅជាអក្ខរកម្មពលរដ្ឋ។ ជំនាញទាំងនោះរួមមាន៖ ការសួរដេញដោលប្រកបដោយការត្រិះរិះពិចារណា បច្ចេកវិទ្យាព័ត៌មាន អក្ខរកម្មសារព័ត៌មាន ការត្រិះរិះពិចារណា ការធ្វើសេចក្ដីសម្រេចចិត្ត ការដោះស្រាយបញ្ហា ការចរចារ ការកសាងសន្តិភាព និងការទទួលខុសត្រូវជាលក្ខណៈបុគ្គលនិងសង្គម។

៤)- ការទទួលស្គាល់ និងពិនិត្យមើលទៅលើជំនឿនិងតម្លៃ និងរបៀបដែលពួកគេមានឥទ្ធិពលទៅលើទស្សនៈ និងការធ្វើសេចក្ដីសម្រេចចិត្តផ្នែកសង្គម និងនយោបាយ ស្ដីអំពីយុត្តិធម៌សង្គម និងការចូលរួមរបស់ពលរដ្ឋ។

៥)- អភិវឌ្ឍឥរិយាបថយកចិត្តទុកដាក់ និងសេចក្ដីអាណិតអាសូរសម្រាប់អ្នកដទៃនិងបរិស្ថាន និងការគោរពចំពោះពិពិធភាព។

៦)- អភិវឌ្ឍតម្លៃនៃភាពត្រឹមត្រូវនិងយុត្តិធម៌សង្គម និងជំនាញក្នុងការវិភាគប្រកបដោយការត្រិះរិះពិចារណាអំពីវិសមភាព ដែលផ្អែកលើភេទ ឋានៈសង្គមសេដ្ឋកិច្ច វប្បធម៌ សាសនា វ័យ និងបញ្ហាផ្សេងៗមួយចំនួនទៀត។

៧)- ចូលរួម និងរួមចំណែកនៅក្នុងបញ្ហាសកល នាសហសម័យនៅក្នុងកម្រិតមូលដ្ឋាន កម្រិតជាតិ និងកម្រិតសកល ក្នុងនាមជាពលរដ្ឋសកល ដែលប្រកបដោយចំណេះដឹង ការចូលរួម ការទទួលខុសត្រូវ និង ការឆ្លើយតប។

ម្យ៉ាងវិញទៀត ការអប់រំពលរដ្ឋសកល អាចដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការចូលរួមទៅក្នុងសមភាពយេនឌ័រ ដែលជាអាទិភាពដ៏សំខាន់មួយក្នុងចំណោមអាទិភាពសំខាន់ទាំងពីររបស់អង្គការយូណេស្កូ។ ការអប់រំភាពជាពលរដ្ឋសកល គឺផ្អែកលើសិទ្ធិមនុស្ស ហើយសមភាពយេនឌ័រគឺជាមូលដ្ឋាននៃសិទ្ធិមនុស្ស។ កុមារានិងកុមារីសិក្សាអំពីឥរិយាបថយេនឌ័រ តួនាទី ការរំពឹងទុក និងអាកប្បកិរិយានៅសាលារៀន ក៏ដូចជានៅឯផ្ទះ។ ការអប់រំភាពជាពលរដ្ឋសកល អាចជួយទ្រទ្រង់សមភាពយេនឌ័រ តាមរយៈការអភិវឌ្ឍចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ដែលលើកកម្ពស់តម្លៃស្មើគ្នារវាងស្ត្រីនិងបុរស បង្កើតឱ្យមានការគោរព និងអនុញ្ញាតឱ្យមនុស្សវ័យក្មេងធ្វើការចោទសួរប្រកបដោយការត្រិះរិះពិចារណា ទៅលើតួនាទីនិងការរំពឹងទុករបស់យេនឌ័រ ដែលអាចបង្កជាគ្រោះថ្នាក់ ឬក៏ជម្រុញឱ្យមានការរើសអើង ឬការគិតបែបអវិជ្ជមានដោយផ្អែកទៅលើយេនឌ័រ។

លទ្ធផលដែលបានមកពីការអប់រំភាពជាពលរដ្ឋសកលនឹងឆ្លើយតបទៅនឹងបណ្ដុំនៃការសិក្សាទាំងបីរួមមាន ចំណេះដឹង ចិត្តសង្គម និងឥរិយាបថ។ ចំពោះចំណេះដឹង នឹងអាចធ្វើឱ្យអ្នកសិក្សាទទួលបានចំណេះដឹងនិងការយល់ដឹង អំពីបញ្ហានៅក្នុងមូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់សកល ព្រមទាំងទំនាក់ទំនងគ្នា និងការអាស្រ័យគ្នាទៅវិញទៅមក រវាងប្រទេសនិងប្រជាជនផ្សេងៗគ្នា។ មិនតែប៉ុណ្ណោះ អ្នកសិក្សានឹងអាចធ្វើការអភិវឌ្ឍន៍ជំនាញសម្រាប់ការត្រិះរិះពិចារណា និងវិភាគ។ ចំណែកឯផ្នែកចិត្តសង្គមវិញ នឹងជួយពិសោធន៍អារម្មណ៍នៃការក្លាយជាផ្នែកមួយនៃមនុស្សជាតិទូទៅ ការចែករំលែក និងការទទួលខុសត្រូវដោយផ្អែកទៅលើសិទ្ធិមនុស្ស ព្រមទាំងអភិវឌ្ឍន៍ឥរិយាបថនៃការអាណិតអាសូរ សាមគ្គីភាព និងការគោរពចំពោះភាពខុសគ្នានិងពិពិធភាព។ ទៅលើផ្នែកឥរិយាបថវិញនោះ នឹងធ្វើឱ្យមានសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការ

ទទួលខុសត្រូវ នៅក្នុងកម្រិតមូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ ក៏ដូចជាពិភពលោកមួយដែលមានសន្តិភាពនិងនិរន្តរភាព និងការបណ្ដុះការស្ម័គ្រចិត្តក្នុងការងារផងដែរ។

## ២.១.៤-សារៈប្រយោជន៍របស់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព

មានហេតុផលជាច្រើនដែល OCB អាចត្រូវបានចាត់ទុកថាសំខាន់។ ហេតុផលទី១ ព្រោះវាអាចធ្វើឱ្យដំណើរការនៃយន្តការសង្គមរបស់អង្គភាពទៅបានដោយរលូន (Smith et al., ឆ្នាំ១៩៨៣)។ ពួកគេបានផ្ដល់នូវភាពបត់បែនដែលលើសពីការផែនការការងារ និងផ្ដល់ទិសដៅដល់ឥរិយាបថការងារដែលអាចកើតឡើងពីពេលមួយទៅពេលមួយតាមតម្រូវការនៃការងារ ឬបរិយាកាសជុំវិញ។ មិនត្រឹមតែឧបករណ៍នេះអាចជួយឱ្យការអនុវត្តបទបញ្ញត្តិការងារក្នុងអង្គភាពបានដោយមិនចាំបាច់ធ្វើការដាស់តឿននោះទេ ក៏ព្រោះថាវាមិនមែនជាផ្នែកមួយនៃតួនាទីការងាររបស់បុគ្គលិកដែលបានចែង ហើយការវាស់វែងឧបករណ៍នេះក៏មានភាពពិបាកដោយសារឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាពរបស់បុគ្គលិកម្នាក់ឬមួយក្រុម អាចធ្វើឱ្យមានការកើនឡើងនៃការប្រព្រឹត្តរបស់បុគ្គលិកផ្សេងទៀត រឺក៏អាចប្រព្រឹត្តបានទាំងអង្គភាពទាំងមូលតែម្ដង។ ដូចនេះហើយទោះបីជាទាំងនោះមិនមែនជាផ្នែកនៃវិធានការនៃការអនុវត្តបទបញ្ញត្តិការងារក៏ដោយ ក៏ OCB នៅតែមានសារៈសំខាន់សម្រាប់ភាពជោគជ័យរយៈពេលវែងរបស់អង្គភាព។

តារាងទី៣.៥- តម្លៃអាល់ហ្វារបស់កម្រងសំណួរនីមួយៗ

| អថេរ | ភាគសំណាកគោលដៅ | |
|---|---|---|
| | ចំនួនផ្នែករង | តម្លៃអាល់ហ្វា |
| ផ្នែកទី១៖ ឧត្តមគតិ | ៥ | ០.៦០ |
| ផ្នែកទី២៖ អត្តទត្តបុគ្គល | ៥ | ០.៧៥ |
| ផ្នែកទី៣៖ និយ័តភាពការងារ | ៥ | ០.៥៧ |
| ផ្នែកទី៤៖ ភាពបម្រុងប្រយ័ត្ន | ៥ | ០.៧២ |
| ផ្នែកទី៥៖ មនុស្សធម៌ការងារ | ៥ | ០.៦៤ |
| **សរុប** | **២៥** | **០.៨១** |

តារាងទី៣.២ ខាងលើ បង្ហាញថា ឧបករណ៍ស្រាវជ្រាវ ជារួម មានភាពជឿជាក់ជាក់អាល់ហ្វាស្ថិតនៅ ០.៨២ បង្ហាញបានថាកម្រងសំណួរស្ថិតក្នុងភាពជឿជាក់កម្រិតល្អ។

### ៣.៣.២- ការត្រួតពិនិត្យគុណភាពឧបករណ៍

អ្នកស្រាវជ្រាវបានបង្កើតឧបករណ៍ដែលប្រើប្រាស់ក្នុងការប្រមូលទិន្នន័យ ដោយមានដំណាក់កាលដូចខាងក្រោម៖

១- សិក្សាគោលការណ៍បញ្ញត្តិទ្រឹស្តី និងចំណេះដឹងទូទៅពាក់ព័ន្ធនឹងឥរិយាបថពលរដ្ឋសកល និងវិធីសាស្ត្រការបង្កើតកម្រងសំណួរតាមទម្រង់កម្រិតការអនុវត្តពីឯកសារស្រាវជ្រាវពាក់ព័ន្ធ។

២- កំណត់គោលបំណង និងក្របខណ្ឌបញ្ញត្តិការសិក្សាស្រាវជ្រាវដើម្បីកំណត់វិសាលភាពសំណួរពាក់ព័ន្ធជាអ្នកដឹកនាំតាមទស្សនៈគ្រូបង្រៀនក្នុងរាជធានីភ្នំពេញ។

៣- បង្កើតកម្រងសំណួរតាមគោលបំណងស្រាវជ្រាវ និងក្របខណ្ឌបញ្ញត្តិការស្រាវជ្រាវ។

៤- យកកម្រងសំណួរដែលបានបង្កើតឡើងដាក់ជូនសាស្ត្រាចារ្យដឹកនាំដើម្បីត្រួតពិនិត្យភាពត្រឹម ត្រូវ និងអនុសាសន៍សម្រាប់យកទៅកែសម្រួល។

៥- យកកម្រងសំណួរដែលបានកែសម្រួលតាមអនុសាសន៍អ្នកជំនាញជូនសាស្ត្រាចារ្យដឹកនាំ ដើម្បីត្រួតពិនិត្យភាពត្រឹមត្រូវម្តងទៀត។

៦- យកកម្រងសំណួរដែលបានកែសម្រួលរួចទៅសាកល្បងប្រើ ( try out ) ជាមួយក្រុមគ្រូបង្រៀននៅកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដែលមិនមែនជាភាគសំណាកសម្រាប់ការសិក្សាចំនួន ៣០នាក់ចេញពី៤សាលាផ្សេងគ្នា និងយកកម្រងសំណួរ ដែលសាកល្បងប្រើនោះមកវិភាគរកភាពជឿជាក់របស់កម្រងសំណួរ។

៧- ធ្វើការកែសម្រួលកម្រងសំណួរដាក់ជូនសាស្ត្រាចារ្យដឹកនាំមុននឹងយកទៅប្រមូលដាក់ស្តែង។

## ៣.៤- វិធីសាស្ត្រប្រមូលទិន្នន័យ

ក្នុងការប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវ បានដំណើរការតាមដំណាក់កាលនីមួយៗដូចខាងក្រោម៖

១- យកលិខិតអនុញ្ញាតិពីវិទ្យាស្ថានអប់រំដែលអនុញ្ញាតិឱ្យចុះប្រមូលទិន្នន័យជូនមន្ទីរអប់រំយុវជននិងកីឡារាជធានីភ្នំពេញ ដើម្បីសុំការអនុញ្ញាតិចុះប្រមូលតាមសាលាគោលដៅទាំង ៦ ខាងលើ។

២- បន្ទាប់ពីបានការអនុញ្ញាតិពីប្រធានមន្ទីរ អ្នកស្រាវជ្រាវ បានចុះប្រមូលទិន្នន័យនៅតាមបណ្តាសាលាវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយជូនលិខិតអនុញ្ញាតិទៅនាយកសាលានីមួយៗ។

៣- អ្នកស្រាវជ្រាវបានប្រមូលផ្ទាល់ជាមួយភាគសំណាក បានប្រមូលផ្ទាល់ជាមួយភាគសំណាកនីមួយៗ ដោយបានពន្យល់យ៉ាងលម្អិតនិងគ្រប់ជ្រុងជ្រោយពីគោលបំណង នៃការស្រាវជ្រាវ និងរយៈពេលការបំពេញកម្រងសំណួរ ដែលក្រុមភាគសំណាក ត្រូវបំពេញ ដោយអ្នកស្រាវជ្រាវ បានបើកទូលាយឱ្យពួកគាត់សាកសួរព័ត៌មានបន្ថែមមុនពួកគាត់បំពេញលើកម្រងសំណួរ។ ភាគសំណាកគោលដៅម្នាក់ៗ បានយល់ព្រមចូលរួមក្នុងការសិក្សាដោយបានចុះហត្ថលេខាលើលិខិតយល់ព្រម ហើយពួកគាត់អាចដកខ្លួនមិនចូលរួមក្នុងការស្រាវជ្រាវបានគ្រប់ពេល។

៤- អ្នកស្រាវជ្រាវ បានប្រមូលកម្រងសំណួរ ដោយពិនិត្យយ៉ាងល្អិតល្អន់ និងភាពត្រឹមត្រូវរបស់កម្រងសំណួរច្បាប់នីមួយៗ។

## ៣.៥- ការវិភាគទិន្នន័យនិងស្ថិតិដែលប្រើក្នុងការវិភាគ

អ្នកស្រាវជ្រាវ បានធ្វើការវិភាគទិន្នន័យ ដែលប្រមូលបានគ្រប់ចំនួនពីភាគសំណាក ដោយរៀបចំការវិភាគតាមប្រភេទទិន្នន័យនិងស្ថិតិតាមលំដាប់លំដាប់ស្តង់ដាសកល។ អ្នកស្រាវជ្រាវ បានត្រួតពិនិត្យភាពត្រឹមត្រូវរបស់កម្រងសំណួរនីមួយៗ ដោយឃើញថា កម្រងសំណួរ មានភាពត្រឹមត្រូវគ្រប់កម្រងសំណួរ និងបានបំពេញលេខកូដកម្រងសំណួរចាប់ពីលេខរៀងទី១ ដល់កម្រងសំណួរលេខរៀងចុងក្រោយអនុលោមតាមទ្រឹស្តីរបស់ប៊េតមេន និង អូហ្គិន (Bateman and Organ, ១៩៨៣)។ តម្លៃអាល់ហ្វា ជារួមរបស់កម្រងសំណួរស្ថិតក្នុងកម្រិត ០.៨២ មានន័យថា សង្គតភាពរបស់កម្រងសំណួរនេះ ស្ថិតក្នុងកម្រិតល្អ (Gorge & Mallery, ២០០៣)។

បន្ទាប់ពីបានរៀបចំទិន្នន័យរួចរាល់ អ្នកស្រាវជ្រាវ បានពិនិត្យកម្រងសំណួរនិងតេស្តនីមួយៗ យ៉ាងយកចិត្តទុកដាក់បំផុត ដោយការវិភាគទិន្នន័យប្រើប្រាស់កុំព្យូទ័រ ដោយប្រើស្ថិតិសំខាន់ៗ គឺៈ ស្ថិតិពិព័ណ៌នា (Descriptive Statistics) និង ស្ថិតិសន្និដ្ឋាន (Inferential Statistics) (Daniel, ២០១៩) រួមជាមួយសកម្មភាពផ្សេងៗជាច្រើនទៀតដូចជាៈ

១- ត្រួតពិនិត្យភាពត្រឹមត្រូវរបស់កម្រងសំណួរនីមួយៗ ដោយឃើញថាត្រឹមត្រូវគ្រប់កម្រងសំណួរ។

២- បំពេញលេខកូដកម្រងសំណួរទី១ ដល់កម្រងសំណួរចុងក្រោយ។

៣- ពិនិត្យដាក់ពិន្ទុកម្រងសំណួរនីមួយៗ ដោយការវិភាគទិន្នន័យប្រើប្រាស់កុំព្យូទ័រ។ នៅពេលដែលរៀបចំទិន្នន័យរួចរាល់ អ្នកស្រាវជ្រាវវិភាគទិន្នន័យ ដូចខាងក្រោមៈ

ក- វិភាគស្ថានភាពរបស់ភាគសំណាក វិភាគដោយប្រើប្រេកង់ (frequency) និងភាគរយ (percentage)។

ខ- វិភាគទស្សនៈគ្រូបង្រៀនលើការអនុវត្តឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព ដោយប្រើតម្លៃមធ្យមភាគ (mean) និង គម្លាតស្តង់ដា (Standard Deviation) Indepent sample-t test និង One-way ANOVA។ តម្លៃ Cronbach's របស់កម្រងសំណួរស្ថិតក្នុងកម្រិត 0.៨២ មានន័យថាសង្គតភាពរបស់កម្រងសំណួរនេះស្ថិតក្នុងកម្រិតល្អ។

### ៣.៥.១- ស្ថិតិដែលប្រើក្នុងការពិនិត្យគុណភាពឧបករណ៍

- សន្ទស្សន៍សមភាព (ioc) ដោយប្រើរូបមន្ត ដូចខាងក្រោម៖

$$IOC = \frac{\sum R}{N}$$

ពេល $IOC$ ជំនួសសន្ទស្សន៍សមភាពរវាងគោលបំណងខ្លឹមសារកម្រងសំណួរ

$\sum R$ ជំនួស លទ្ធផលសរុបពិន្ទុការយល់ឃើញ

$N$ ជំនួស ចំនួនអ្នកជំនាញទាំងអស់

### ៣.៥.២- អំណាចចំណែក (Discrimination)

ការពិសោធន៍តម្លៃតាមចំណុចនីមួយៗ មានរូបមន្ត ដូចខាងក្រោម៖

$$t = \frac{\bar{X}1 - \bar{X}2}{\sqrt{\frac{S_1^2}{N_1} + \frac{S_2^2}{N_2}}}$$

ពេល t ជំនួស តម្លៃស្ថិតិដែលប្រើពិសោធន៍តម្លៃធី

$\bar{X}_1$ ជំនួស តម្លៃមធ្យមភាគរបស់ក្រុមទីភាគសំណាកទី១

$\bar{X}_2$ ជំនួស តម្លៃមធ្យមភាគរបស់ក្រុមទីភាគសំណាកទី២

$S_1^2$ ជំនួស ភាពប្រែប្រួលរបស់ក្រុមទីភាគសំណាកទី១

$S_2^2$ ជំនួស ភាពប្រែប្រួលរបស់ក្រុមទីភាគសំណាកទី២

$N_1$ ជំនួស ចំនួនមនុស្សក្នុងភាគសំណាកទី១

$N_2$ ជំនួស ចំនួនមនុស្សក្នុងភាគសំណាកទី២

### ៣.៥.៣- ភាពជឿជាក់ ( $\alpha$ )

តាមវិធីរបស់គ្រន់បាគ (cronbach) មានរូបមន្ត ដូចខាងក្រោម៖

ពេល $\alpha$ ជំនួស តម្លៃប្រសិទ្ធភាពអែលហ្វារបស់ភាពជឿជាក់

K ជំនួស ចំនួនចំណុចដែលត្រូវវាស់

$S_i^2$ ជំនួស ចំនួនភាពប្រែប្រួលរបស់ចំណុចនីមួយៗ

$S_t^2$ ជំនួស ចំនួនភាពប្រែប្រួលរបស់ឧបករណ៍ទាំងច្បាប់

### ៣.៥.៤- ស្ថិតិមូលដ្ឋាន

**១- ភាគរយ** (percenatge) ដោយប្រើរូបមន្ត ដូចខាងក្រោម៖

$$\% = \frac{f}{N} \times 100$$

ពេល % ជំនួស ភាគរយ

$f$ ជំនួស ប្រេកង់ដែលត្រូវការប្រែជាភាគរយ

$N$ ជំនួស ភាគសំណាក

**២- មធ្យមភាគ** (mean) ដោយប្រើរូបមន្ត ដូចខាងក្រោម៖

$$\bar{X} = \frac{\sum X}{N}$$

ពេល $\bar{X}$ ជំនួស មធ្យមភាគ

$\sum X$ ជំនួស លទ្ធផលរួមរបស់ទិន្នន័យឬពិន្ទុ

$N$ ជំនួស ចំនួនទិន្នន័យ

៣- **គម្លាតស្តង់ដា** (standard deviation) ដោយប្រើរូបមន្ត ដូចខាងក្រោម៖

$$SD = \sqrt{\frac{N\sum X^2 - (\sum X)^2}{N(N-1)}}$$

ពេល $S.D.$ ជំនួស តម្លៃគម្លាតស្តង់ដា

$\sum X^2$ ជំនួស លទ្ធផលរួមរបស់ពិន្ទុការ៉េនីមួយៗ

$(\sum X)^2$ ជំនួស លទ្ធផលរួមរបស់ពិន្ទុការ៉េទាំងអស់

$N$ ជំនួស ចំនួនភាគសំណាក

## ៣.៦- ក្រមសីលធម៌នៃការស្រាវជ្រាវ

រាល់កិច្ចសិក្សាស្រាវជ្រាវ បញ្ហាក្រមសីលធម៌អាចកើតមានឡើងស្ទើរគ្រប់ដំណាក់កាលនៃនីតិវិធីការស្រាវជ្រាវ។ គ្រីសវែល (Cresswell, ២០០៣) បានណែនាំនិងផ្តល់អនុសាសន៍ថា បញ្ហាក្រមសីលធម៌នៃការស្រាវជ្រាវ ចាំបាច់ត្រូវយកមកគិតពិចារណាទៅតាមដំណាក់កាលនីមួយៗនៃការសរសេរនិក្ខេបបទ។ ប្រការនេះ បញ្ហាក្រមសីលធម៌សម្រាប់ការសិក្សានេះ ត្រូវបានយកមកអនុវត្តយ៉ាងយកចិត្តទុកដាក់នៅគ្រប់ដំណាក់កាលនីមួយៗយ៉ាងម៉ត់ចត់បំផុត។ លើសពីនេះទៅទៀត រាល់ទិន្នន័យផ្ទាល់ខ្លួនរបស់ភាគសំណាកទាំងអស់ដែលប្រមូលបានសម្រាប់ប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ ត្រូវបានរក្សាជាកិច្ចសម្ងាត់បំផុត និងមិនត្រូវបានបញ្ចេញជាសាធារណៈឡើយ។

# ជំពូកទី៤

# លទ្ធផលនៃការស្រាវជ្រាវ និងពិភាក្សា

# ជំពូក៤

# លទ្ធផលនៃការស្រាវជ្រាវ និងពិភាក្សា

ការវិភាគទិន្នន័យ នៃការសិក្សាស្រាវជ្រាវ ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ អ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យ និងបង្ហាញលទ្ធផលការវិភាគទិន្នន័យតាមចំណុចសំខាន់ស្របតាមគោលបំណងនៃការស្រាវជ្រាវ ដោយបែងចែកជា ២ ផ្នែករៀងតាមលំដាប់ដូចខាងក្រោម៖

**ផ្នែកទី១៖** លទ្ធផលការវិភាគ លើឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យ ក្នុងរាជធានីភ្នំពេញចំនួន ៥ ផ្នែក។

**ផ្នែកទី២៖** ការវាស់ស្ទង់ឥរិយាបថគ្រូបង្រៀនក្នុងអង្គភាពកម្រិតវិទ្យាល័យ ក្នុងរាជធានីភ្នំពេញដោយបែងចែកតាមភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍ការបង្រៀន។

## ៤.១- លទ្ធផលការស្រាវជ្រាវ

### ៤.១.១- លទ្ធផលការស្រាវជ្រាវទិន្នន័យផ្នែកទី១

ផ្នែកទី១ នេះ គឺបកស្រាយសំណួរការស្រាវជ្រាវទី១ "តើទស្សនៈរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ទៅលើឥរិយាបថភាពជាពលរដ្ឋសកលស្ថិតក្នុងកម្រិតណា?"។ គោលបំណងនៃសំណួរទី១នេះ ដើម្បីដឹងពីស្ថានភាពឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀនក្នុងអង្គភាពសាលារៀន។ ឧបករណ៍ការស្រាវជ្រាវនេះ គឺកម្រងសំណួរដែលបានដកស្រង់ពីទ្រឹស្តីរបស់បេើតមេន និងអូហ្គិន Batman and Organ (១៩៨៣) ដែលចែកចេញជា ៥ ផ្នែក មាន ២៥ ចំណុច។ ការវិភាគទិន្នន័យ គឺប្រើប្រាស់តម្លៃមធ្យម និងគម្លាតស្តង់ដា។ លទ្ធផលផ្នែកទី១ ត្រូវបានបង្ហាញតាមតារាង ដូចខាងក្រោម៖

**តារាងទី៤.១- ចំនួនភាគសំណាកបែងចែកតាមភេទ (N=២២៧)**

| ភេទ | ចំនួន | ភាគរយ |
|---|---|---|

| | | |
|---|---|---|
| ស្រី | **៩៣** | **៤១.០** |
| ប្រុស | **១៤៣** | **៥៩.០** |

តាមរយៈតារាងខាងលើ ចំនួនភាគសំណាកសរុបចំនួន២២៧នាក់ ត្រូវបានបែងចែកជា២ភេទគឺ ភេទប្រុស និងភេទស្រី ដោយភេទស្រីមានចំនួន ៩៣នាក់ ស្មើនឹង ៤១.០ ភាគរយ និងភេទប្រុសមានចំនួន ១៤៣ នាក់ ស្មើនឹង ៥៩.០ ភាគរយ។

**តារាងទី៤.២- ចំនួនភាគសំណាកបែងចែកតាមអាយុ (N=២២៧)**

| អាយុ | ចំនួន | ភាគរយ |
|---|---|---|
| **ក្រោម៣០ឆ្នាំ** | ២៥ | ១១.០ |
| **៣០-៤៥ឆ្នាំ** | ១៣៤ | ៥៩.០ |
| **លើសពី៤៥ឆ្នាំ** | ៦៨ | ៣០.០ |

តាមរយៈតារាងខាងលើចំនួនភាគសំណាកសរុបចំនួន ២២៧នាក់ ត្រូវបានបែងចែកតាមអាយុជា ៣ កម្រិត ដោយអាយុក្រោម៣០ឆ្នាំ មានចំនួន ២៥នាក់ ស្មើនឹង ១១.០ ភាគរយ អាយុ៣០ដល់៤៥ឆ្នាំ មានចំនួន ៦៨នាក់ ស្មើនឹង ៥៩.០ ភាគរយ និងអាយុលើសពី៤៥ឆ្នាំ មានចំនួន ៦៨នាក់ ស្មើនឹង ៣០.០ភាគរយ។

**តារាងទី៤.៣- ចំនួនភាគសំណាកបែងចែកតាមគុណវុឌ្ឍិ (N=២២៧)**

| កម្រិតគុណវុឌ្ឍិ | ចំនួន | ភាគរយ |
|---|---|---|
| **ក្រោមបរិញ្ញាបត្រ** | ៤៥ | ១៩.៨ |
| **បរិញ្ញាបត្រ** | ១៤៣ | ៦៣.០ |
| **ខ្ពស់ជាងបរិញ្ញាបត្រ** | ៣៩ | ១៧.២ |

តាមរយៈតារាងខាងលើ ចំនួនភាគសំណាកបែងចែកតាមគុណវុឌ្ឍិជា៣កម្រិតគឺ កម្រិតក្រោមបរិញ្ញាបត្រដែលមានចំនួន ៤៥នាក់ ស្មើនឹង ១៩.៨ ភាគរយ កម្រិតបរិញ្ញាបត្រចំនួន ១៤៣នាក់ ស្មើនឹង ៦៣.០ ភាគរយ និងកម្រិតខ្ពស់ជាងបរិញ្ញាបត្រចំនួន ៣៩ នាក់ ស្មើនឹង ១៧.២ ភាគរយ។

**តារាងទី៤.៤- ចំនួនភាគសំណាកបែងចែកតាមបទពិសោធន៍ (N=២២៧)**

| បទពិសោធន៍ | ចំនួន | ភាគរយ |
|---|---|---|
| **តិចជាង៥ឆ្នាំ** | ២៥ | ១១.0 |
| **៥-១០ឆ្នាំ** | ៤៤ | ១៩.៤ |
| **លើសពី១០ឆ្នាំ** | ១៥៨ | ៦៩.៦ |

ចំនួនភាគសំណាកត្រូវបានបែងចែកតាមបទពិសោធន៍បង្រៀន ដោយគ្រូបង្រៀនដែលមានបទពិសោធន៍តិចជាង៥ឆ្នាំចំនួន ២៥នាក់ ស្មើនឹង ១១.០ភាគរយ គ្រូបង្រៀនដែលមានបទពិសោធន៍៥ទៅ១០ឆ្នាំ មានចំនួន ៤៤នាក់ ស្មើនឹង១៩.៤ ភាគរយ និងគ្រូបងរៀនដែលមានបទពិសោធន៍លើសពី១០ឆ្នាំចំនួន ១៥៨ នាក់ ស្មើនឹង ៦៩.៦ ភាគរយ។

**តារាងទី៤.៥- តម្លៃមធ្យម គម្លាតស្តង់ដារ អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនតាមចំណុចនីមួយៗ (N=២២៧)**

| ល.រ | ឥរិយាបថពលរដ្ឋសកលក្នុងអង្គភាព | M | S.D. | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| ១- | ខ្ញុំបាទ/នាងខ្ញុំតែងតែធ្វើការងារនៅសាលារៀនលើសពីនិយាមកំណត់ | ៣.១១ | 0.៩៦៣ | មធ្យម | ២៣ |
| ២- | ខ្ញុំបាទ/នាងខ្ញុំមិនដែលចំណាយពេលច្រើនក្នុងការត្អូញត្អែរអំពីរឿងតូចតាចក្នុងសាលា | ៤.៦៩ | 0.៨00 | ខ្ពស់បំផុត | ២ |
| ៣- | ខ្ញុំបាទ/នាងខ្ញុំតែងតែចូលរួមប្រជុំទោះបីជាមិនមែនជាកាតព្វកិច្ចក៏ដោយឱ្យតែជាការងារសំខាន់សម្រាប់សាលា | ៤.0៨ | 0.៧៥៤ | ខ្ពស់ | ១៤ |
| ៤- | ខ្ញុំបាទ/នាងខ្ញុំបានរកវិធីសាស្ត្រដើម្បីការពារកុំឱ្យមានបញ្ហាជាមួយមិត្តរួមការងារ | ៤.៣១ | 0.៨៨៤ | ខ្ពស់ | ៨ |
| ៥- | ខ្ញុំបាទ/នាងខ្ញុំតែងតែជួយលោកគ្រូអ្នកគ្រូផ្សេងទៀតពេលគាត់អវត្តមាន | ៣.៥៩ | ១.២0៦ | ខ្ពស់ | ២0 |
| ៦- | ខ្ញុំបាទ/នាងខ្ញុំមិនដែលចំណាយពេលទំនេរនៅសាលានោះទេ | ២.៣៨ | ១.១២0 | មធ្យម | ២៥ |

| | | | | | |
|---|---|---|---|---|---|
| ៧- | ខ្ញុំបាទ/នាងខ្ញុំតែងតែផ្តោតលើចំណុចវិជ្ជមានជាងចំណុចអវិជ្ជមាន | ៤.៤៥ | ១.០៦១ | ខ្ពស់ | ៤ |
| ៨- | ខ្ញុំបាទ/នាងខ្ញុំតែងតែចូលរួមគ្រប់កិច្ចការនានា ទោះបីមិនមែនជាកាតព្វកិច្ចក៏ដោយឱ្យតែរួមចំណែកជួយសាលាបាន | ៣.៩៦ | ០.៨៧២ | ខ្ពស់ | ១៦ |
| ៩- | ខ្ញុំបាទ/នាងខ្ញុំតែងតែយកចិត្តទុកដាក់មិនឱ្យសកម្មភាពខ្លួនប៉ះពាល់ដល់មិត្តរួមការងារ | ៣.៥២ | ១.៥៦៩ | ខ្ពស់ | ២១ |
| ១០- | ខ្ញុំបាទ/នាងខ្ញុំតែងតែជួយលោកគ្រូអ្នកគ្រូ ឬ បុគ្គលិកផ្សេងទៀតពេលមានការងាររវល់ច្រើន | ៣.៩៨ | ០.៩៤៧ | ខ្ពស់ | ១៥ |
| ១១- | ខ្ញុំបាទ/នាងខ្ញុំបានគោរពច្បាប់សាលានិងបទបញ្ជាផ្ទៃក្នុងរបស់សាលាយ៉ាងខ្ជាប់ខ្ជួន | ៤.៥៥ | ០.៧៣៦ | ខ្ពស់បំផុត | ៣ |
| ១២- | ខ្ញុំបាទ/នាងខ្ញុំគឺជាមនុស្សដែលចំណាយពេលវេលាច្រើនសម្រាប់រឿងផ្ទាល់ខ្លួន | ៣.៨៨ | ១.៣៥៤ | ខ្ពស់ | ១៧ |
| ១៣- | ខ្ញុំបាទ/នាងខ្ញុំតែងតែគាំទ្រវាល់ការវិវត្តថ្មីនៅក្នុងសាលា | ៤.៤៤ | ០.៧៨២ | ខ្ពស់ | ៥ |
| ១៤- | ខ្ញុំបាទ/នាងខ្ញុំមិនដែលរំលោភបំពានសិទ្ធិអ្នកដទៃក្នុងសាលារៀននោះទេ | ៤.២៥ | ២.២១៧ | ខ្ពស់ | ១០ |
| ១៥- | ខ្ញុំបាទ/នាងខ្ញុំតែងតែជួយបង្ហាត់បង្រៀន និង ណែនាំលោកគ្រូបង្រៀនចូលថ្មីទោះបីមិនមែនជាកាតព្វកិច្ចខ្ញុំ | ៣.៧២ | ១.១៦៦ | ខ្ពស់ | ១៨ |
| ១៦- | ខ្ញុំបាទ/នាងខ្ញុំគឺជាគ្រូម្នាក់ដែលមានស្មារតីទទួលខុសត្រូវខ្ពស់បំផុតលើការងារ | ៤.៤៤ | ០.៧៩៨ | ខ្ពស់ | ៦ |
| ១៧- | ខ្ញុំបាទ/នាងខ្ញុំមិនដែលចាប់កំហុសការងារអ្នកដទៃក្នុងសាលាខ្ញុំ | ៤.៨០ | ០.៦៨១ | ខ្ពស់បំផុត | ១ |
| ១៨- | ខ្ញុំបាទ/នាងខ្ញុំតែងតែអាននិងអនុវត្តនូវរាល់សេចក្តីប្រកាសនានារបស់សាលា ឬអនុសារណៈផ្សេងៗជាដើម | ៤.៣១ | ០.៨៧៤ | ខ្ពស់ | ៩ |

| | | | | | |
|---|---|---|---|---|---|
| **១៩-** | ខ្ញុំបាទ/នាងខ្ញុំព្យាយាមគេចចេញពីការបង្ករបញ្ហាក្នុងសាលារៀន | ៣.០៨ | ១.៦៨៩ | មធ្យម | ២៤ |
| **២០-** | ខ្ញុំបាទ/នាងខ្ញុំមានឆន្ទៈខ្ពស់ក្នុងការជួយដោះស្រាយបញ្ហារបស់មិត្តរួមការងារ | ៤.១៥ | ០.៨៩៣ | ខ្ពស់ | ១២ |
| **២១-** | ខ្ញុំបាទ/នាងខ្ញុំមានឆន្ទៈខ្ពស់ក្នុងការអនុវត្តការងារប្រចាំថ្ងៃ | ៤.៣៩ | ០.៩០៣ | ខ្ពស់ | ៧ |
| **២២-** | ខ្ញុំបាទ/នាងខ្ញុំតែងតែផ្តោតលើដំណោះស្រាយជាងបញ្ហា | ៤.១៣ | ១.០៦៧ | ខ្ពស់ | ១៣ |
| **២៣-** | ខ្ញុំបាទ/នាងខ្ញុំតែងតែធ្វើខ្លួនជាមនុស្សមានប្រយោជន៍សម្រាប់សាលា"ដោះអំរែកចេញពីស្មា" | ៣.៧១ | ០.៩១៣ | ខ្ពស់ | ១៩ |
| **២៤-** | ខ្ញុំបាទ/នាងខ្ញុំតែងចាត់ទុកសកម្មភាពប៉ះពាល់ទៅលើមិត្តរួមការងារជារឿងធំ | ៣.៥០ | ១.១២២ | ខ្ពស់ | ២២ |
| **២៥-** | ខ្ញុំបាទ/នាងខ្ញុំតែងតែត្រៀមខ្លួនជានិច្ចក្នុងការជួយអ្នកជុំវិញខ្លួន | ៤.១៨ | ០.៨៤៩ | ខ្ពស់ | ១១ |
| | **សរុប** | **៣.៩៨** | **០.៤៥១** | **ខ្ពស់** | |

តាមតារាងខាងលើ លទ្ធផលបង្ហាញឱ្យឃើញថា បរិយាកាសអង្គភាពតាមទស្សនៈគ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិជារួមក្នុងកម្រិតមធ្យម (M=៣.៤២, S.D.=0.៤១៤)។ បើរៀងលំដាប់តម្លៃមធ្យមភាគខ្លឹមសារចំណុចចំនួនបី ដែលមានតម្លៃខ្ពស់ជាងគេគឺចំណុចទី១១ "គោរពច្បាប់សាលានិងបទបញ្ជាផ្ទៃក្នុងរបស់សាលាយ៉ាងខ្ជាប់ខ្ជួន ស្ថិតក្នុងកម្រិតខ្ពស់ (M=៤.៥៥, S.D.=0.៧៣៦)" និងចំណុចទី១៣ "ការគាំទ្រលំការវិវត្តថ្មីនៅក្នុងសាលា (M=៤.៤៤, S.D.=0.៧៨២)" តាមលំដាប់។

ផ្ទុយទៅវិញ បើរៀបតាមលំដាប់តម្លៃមធ្យម ផ្នែកបួនក្នុងតារាងខាងលើនេះដែលទាបជាងគេគឺចំណុចទី១៧ "ការចាប់កំហុសការងារអ្នកដទៃក្នុងសាលា(M=១.២០, S.D.=0.៦៨១)" ចំណុចទី២ "ការចំណាយពេលច្រើនក្នុងការត្អូញត្អែរអំពីរឿងក្នុងសាលា (M=១.២២, S.D.=0.៦០៨)" ចំណុចទី៧ "ការផ្តោតលើចំណុចអវិជ្ជមានជាងចំណុចវិជ្ជមាន(M=១.៥៤, S.D.=១.០៥៧)" និងចំណុចទី២២ "ការផ្តោតលើបញ្ហា

ជាងដំណោះស្រាយ(M=១.៨៨, S.D.=១.០៨៧)"។ លទ្ធផលតាមផ្នែកទាំង ៨ នឹងបង្ហាញនៅតារាងទី២ ខាងក្រោម៖

**តារាងទី៤.៦- តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង៥ (N=២២៧)**

| ល.រ | ឥរិយាបថពលរដ្ឋសកលក្នុងអង្គភាព | M | S.D. | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| ១- | ឧត្តមគតិការងារ | ៣.៧៧ | ០.៥៦ | ខ្ពស់ | ៤ |
| ២- | អត្តទត្ថបុគ្គល | ៤.៣៩ | ០.៥១ | ខ្ពស់ | ១ |
| ៣- | និយ័តភាពការងារ | ៤.១០ | ០.៥៩ | ខ្ពស់ | ២ |
| ៤- | ភាពបម្រុងប្រយ័ត្ន | ៣.៧៣ | ០.៧៧ | ខ្ពស់ | ៥ |
| ៥- | មនុស្សធម៌ការងារ | ៣.៩២ | ០.៨១ | ខ្ពស់ | ៣ |
| | **សរុប** | **៣.៩៨** | **០.៥១** | **ខ្ពស់** | |

តាមតារាងខាងលើ លទ្ធផលស្រាវជ្រាវបង្ហាញថា ឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀនក្នុងអង្គភាពគ្រប់ផ្នែកស្ថិតក្នុងកម្រិត**ខ្ពស់** ទាំងអស់។

បើរៀបតាមតម្លៃមធ្យម លទ្ធផលបង្ហាញថាផ្នែក "អត្តទត្ថបុគ្គល" ស្ថិតនៅលំដាប់ទី១ ដែលមានតម្លៃមធ្យម ៣.៣៩ និងគម្លាតស្តង់ដា ០.៥១ ផ្នែក "និយ័តភាពការងារ" ស្ថិតក្នុងលំដាប់ទី២ ដែលមានតម្លៃមធ្យម ៤.១០ និងគម្លាតស្តង់ដា ០.៥៩ ផ្នែក "មនុស្សធម៌ការងារ" ស្ថិតក្នុងលំដាប់ទី៣ ដែលមានតម្លៃមធ្យម ៣.៩២ និងគម្លាតស្តង់ដា ០.៨១ ផ្នែក "ឧត្តមគតិការងារ" ស្ថិតក្នុងលំដាប់ទី៤ ដែលមានតម្លៃមធ្យម ៣.៧៧ និងគម្លាតស្តង់ដា ០.៥៦ និងផ្នែកដែលទទួលបានលទ្ធផលទាបជាងគេក្នុងចំណោម៥ចំណុចខាងលើគឺផ្នែកទី៤ ដែលមានតម្លៃមធ្យម ៣.៧៣ និងគម្លាតស្តង់ដា ០.៧៧។

**តារាងទី៤.៧- តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង៥ និងតាមចំណុចនីមួយៗ (N=២២៧)**

| ល.រ | ឥរិយាបថពលរដ្ឋសកលក្នុងអង្គភាព | M | S.D. | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| **ផ្នែកទី១ ឧត្តមគតិការងារ** | | | | | |
| ១- | ខ្ញុំបាទ/នាងខ្ញុំតែងតែធ្វើការងារនៅសាលារៀនលើសពីនិយាមកំណត់ | ៣.១១ | ០.៩៦៣ | មធ្យម | ១៨ |
| ៦- | ខ្ញុំបាទ/នាងខ្ញុំមិនដែលចំណាយពេលទំនេរនៅសាលានោះទេ | ២.៣៨ | ១.១២០ | មធ្យម | ២០ |
| ១១- | ខ្ញុំបាទ/នាងខ្ញុំបានគោរពច្បាប់សាលានិងបទបញ្ជាផ្ទៃក្នុងរបស់សាលាយ៉ាងខ្ជាប់ខ្ជួន | ៤.៥៥ | ០.៧៣៦ | ខ្ពស់បំផុត | ១ |
| ១៦- | ខ្ញុំបាទ/នាងខ្ញុំគឺជាគ្រូម្នាក់ដែលមានស្មារតីទទួលខុសត្រូវខ្ពស់បំផុតលើការងារ | ៤.៤៤ | ០.៧៩៨ | ខ្ពស់ | ២ |
| ២១- | ខ្ញុំបាទ/នាងខ្ញុំមានឆន្ទៈខ្ពស់ក្នុងការអនុវត្តការងារប្រចាំថ្ងៃ | ៤.៣៩ | ០.៩០៣ | ខ្ពស់ | ៤ |
| | **សរុប** | **៣.៧៧** | **០.៥៦០** | **ខ្ពស់** | **៤** |
| **ផ្នែកទី២ អត្តទត្ថបុគ្គល** | | | | | |
| ២- | ខ្ញុំបាទ/នាងខ្ញុំមិនដែលចំណាយពេលច្រើនក្នុងការត្អូញត្អែរអំពីរឿងតូចតាចក្នុងសាលា | ៤.៦៩ | ០.៨០០ | ខ្ពស់បំផុត | ២ |
| ៧- | ខ្ញុំបាទ/នាងខ្ញុំតែងតែផ្តោតលើចំណុចវិជ្ជមានជាងចំណុចអវិជ្ជមាន | ៤.៤៥ | ១.០៦១ | ខ្ពស់ | ៤ |
| ១២- | ខ្ញុំបាទ/នាងខ្ញុំគឺជាមនុស្សមិនដែលចំណាយពេលវេលាច្រើនសម្រាប់រឿងផ្ទាល់ខ្លួន | ៣.៨៨ | ១.៣៥៤ | ខ្ពស់ | ១៧ |
| ១៧- | ខ្ញុំបាទ/នាងខ្ញុំមិនដែលចាប់កំហុសការងារអ្នកដទៃក្នុងសាលានោះទេ | ៤.៨០ | ០.៦៨១ | ខ្ពស់បំផុត | ១ |
| ២២- | ខ្ញុំបាទ/នាងខ្ញុំតែងតែផ្តោតលើដំណោះស្រាយបញ្ហាជាង | ៤.១៣ | ១.០៦៧ | ខ្ពស់ | ១៣ |
| | **សរុប** | **៣.៧៧** | **០.៥៥៦** | **ខ្ពស់** | **១** |
| **ផ្នែកទី ៣ និយ័តភាពការងារ** | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៣- | ខ្ញុំបាទ/នាងខ្ញុំតែងតែចូលរួមប្រជុំទោះបីជាមិនមែនជាកាតព្វកិច្ចក៏ដោយឱ្យតែជាការងារសំខាន់សម្រាប់សាលា | ៤.០៨ | ០.៧៥៤ | ខ្ពស់ | ១០ |
| ៨- | ខ្ញុំបាទ/នាងខ្ញុំតែងតែចូលរួមគ្រប់កិច្ចការនានាទោះបីមិនមែនជាកាតព្វកិច្ចក៏ដោយឱ្យតែរួមចំណែកជួយសាលាបាន | ៣.៩៦ | ០.៨៧២ | ខ្ពស់ | ១២ |
| ១៣- | ខ្ញុំបាទ/នាងខ្ញុំតែងតែគាំទ្ររាល់ការវិវត្តថ្មីនៅក្នុងសាលា | ៤.៤៤ | ០.៧៨២ | ខ្ពស់ | ២ |
| ១៨- | ខ្ញុំបាទ/នាងខ្ញុំតែងតែអាននិងអនុវត្តនូវរាល់សេចក្ដីប្រកាសនានារបស់សាលា ឬអនុសារណៈផ្សេងៗជាដើម | ៤.៣១ | ០.៨៧៤ | ខ្ពស់ | ៥ |
| ២២- | ខ្ញុំបាទ/នាងខ្ញុំតែងតែផ្ដោតលើបញ្ហាជាងដំណោះស្រាយ | ១.៨៨ | ១.០៧៨ | ទាប | ២២ |
| | **សរុប** | **៤.១០** | **០.៥៩៤** | **ខ្ពស់** | **២** |
| **ផ្នែកទី ៤ ភាពបម្រុងប្រយ័ត្ន** | | | | | |
| ៤- | ខ្ញុំបាទ/នាងខ្ញុំបានរកវិធីសាស្ត្រដើម្បីការពារកុំឱ្យមានបញ្ហាជាមួយមិត្តរួមការងារ | ៤.៣១ | ០.៨៨៤ | ខ្ពស់ | ៥ |
| ៩- | ខ្ញុំបាទ/នាងខ្ញុំតែងតែយកចិត្តទុកដាក់មិនឱ្យសកម្មភាពខ្លួនប៉ះពាល់ដល់មិត្តរួមការងារ | ៣.៥២ | ១.៥៦៩ | ខ្ពស់ | ១៦ |
| ១៤- | ខ្ញុំបាទ/នាងខ្ញុំមិនដែលរំលោភបំពានសិទ្ធិអ្នកដទៃក្នុងសាលារៀននោះទេ | ៤.២៥ | ២.២១៧ | ខ្ពស់ | ៧ |
| ១៩- | ខ្ញុំបាទ/នាងខ្ញុំព្យាយាមគេចចេញពីការបង្ករបញ្ហាក្នុងសាលារៀន | ៣.០៨ | ១.៦៨៩ | មធ្យម | ១៩ |
| ២៤- | ខ្ញុំបាទ/នាងខ្ញុំតែងចាត់ទុកសកម្មភាពប៉ះពាល់ទៅលើមិត្តរួមការងារជារឿងធំ | ៣.៥០ | ១.១២២ | ខ្ពស់ | ១៧ |
| | **សរុប** | **៣.៧៣** | **០.៧៧២** | **ខ្ពស់** | **៥** |
| **ផ្នែកទី ៥ មនុស្សធម៌ការងារ** | | | | | |

| | | | | | |
|---|---|---|---|---|---|
| **៥-** | ខ្ញុំបាទ/នាងខ្ញុំតែងតែជួយលោកគ្រូអ្នកគ្រូផ្សេងទៀតពេលគាត់អវត្តមាន | ៣.៥៩ | ១.២០៦ | ខ្ពស់ | ១៥ |
| **១០-** | ខ្ញុំបាទ/នាងខ្ញុំតែងតែជួយលោកគ្រូអ្នកគ្រូ ឬ បុគ្គលិកផ្សេងទៀតពេលមានការងាររវល់ច្រើន | ៣.៩៨ | ០.៩៤៧ | ខ្ពស់ | ១១ |
| **១៥-** | ខ្ញុំបាទ/នាងខ្ញុំតែងតែជួយបង្ហាត់បង្រៀន និង ណែនាំលោកគ្រូបង្រៀនចូលថ្មីទោះបីមិនមែនជាកាតព្វកិច្ចខ្ញុំ | ៣.៧២ | ១.១៦៦ | ខ្ពស់ | ១៣ |
| **២០-** | ខ្ញុំបាទ/នាងខ្ញុំមានឆន្ទៈខ្ពស់ក្នុងការជួយដោះស្រាយបញ្ហារបស់មិត្តរួមការងារ | ៤.១៥ | ០.៨៩៣ | ខ្ពស់ | ៩ |
| **២៥-** | ខ្ញុំបាទ/នាងខ្ញុំតែងតែត្រៀមខ្លួនជានិច្ចក្នុងការជួយអ្នកជុំវិញខ្លួន | ៤.១៨ | ០.៨៤៩ | ខ្ពស់ | ៨ |
| | សរុប | ៣.៩២ | ០.៨១០ | ខ្ពស់ | ៣ |

ដូចដែលបានរៀបរាប់ក្នុងតារាងខាងលើ លទ្ធផលបង្ហាញថាទស្សនៈរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ តាមផ្នែកនិងតាមចំណុចស្ថិតក្នុងលំដាប់ខ្ពស់។ ផ្នែកដែលទទួលបានលទ្ធផលខ្ពស់ជាងគេគឺផ្នែក "អត្តទត្តបុគ្គល" តាមដោយផ្នែក "និយ័តភាពការងារ" និង "មនុស្សធម៌ការងារ"។ ផ្នែកដែលទទួលបានលទ្ធផលទាបជាងគេក្នុងចំណោមផ្នែកទាំង៥គឺផ្នែក "ភាពបម្រុងប្រយ័ត្ន" តាមដោយផ្នែក "ឧត្តមគតិការងារ"។

**តារាងទី៤.៨- តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព តាមទស្សនៈគ្រូបង្រៀនតាមផ្នែកទាំង ៥ ដោយបែងចែកតាមភេទ (N=២២៧)**

| ល.រ | ឥរិយាបថពលរដ្ឋសកលក្នុងអង្គភាព | ប្រុស | | | ស្រី | | |
|---|---|---|---|---|---|---|---|
| | | M | S.D. | អត្ថន័យ | M | S.D. | អត្ថន័យ |
| ១- | ឧត្តមគតិការងារ | ៣.៨៨ | ០.៥០៦ | ខ្ពស់ | ៣.៦២ | ០.៦០១ | ខ្ពស់ |
| ២- | អត្តទត្តបុគ្គល | ៤.៣៧ | ០.៥២៤ | ខ្ពស់ | ៤.៤២ | ០.៤៩៧ | ខ្ពស់ |
| ៣- | និយ័តភាពការងារ | ៤.១៦ | ០.៥៤៤ | ខ្ពស់ | ៤.០២ | ០.៦៥៥ | ខ្ពស់ |
| ៤- | ភាពបម្រុងប្រយ័ត្ន | ៣.៦៧ | ០.៧៣៨ | ខ្ពស់ | ៣.៨២ | ០.៨១៥ | ខ្ពស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥- | មនុស្សធម៌ការងារ | ៤.០៨ | ០.៨២៣ | ខ្ពស់ | ៣.៧០ | ០.៧៤១ | ខ្ពស់ |
| | **សរុប** | **៤.០៣** | **០.៤១០** | **ខ្ពស់** | **៣.៩២** | **០.៥០០** | **ខ្ពស់** |

ដូចដែលបានបង្ហាញក្នុងតារាងខាងលើ លទ្ធផលបង្ហាញថា ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យដោយបែងចែកតាមភេទ ស្ថិតក្នុងកម្រិតខ្ពស់គ្រប់ផ្នែក។ បើយើងធ្វើការប្រៀបធៀបតាមភេទ យើងសង្កេតឃើញថាលទ្ធផលរបស់គ្រូបង្រៀនភេទប្រុស គឺខ្ពស់ជាង គ្រូបង្រៀនភេទស្រី។ តម្លៃមធ្យមសរុបភេទប្រុស ៤.០៣ និងគម្លាតស្តង់ដា ០.៤១ ចំណែកឯតម្លៃមធ្យមភេទស្រី ៣.៩២ និងគម្លាតស្តង់ដា ០.៥០។

បើយើងធ្វើការប្រៀបធៀបលើផ្នែកចំនួន៥ខាងលើ លទ្ធផលបង្ហាញថាភេទប្រុសលើផ្នែក "អត្តទត្ថបុគ្គល" ខ្ពស់ជាងគេដែលមានតម្លៃមធ្យម ៤.៣៧ និងមានគម្លាតស្តង់ដា ០.៥២ តាមដោយផ្នែក "និយ័តភាពការងារ" ដែលមានតម្លៃមធ្យម ៤.១៦ និងគម្លាតស្តង់ដា ០.៥៤។ ចំណែកឯលទ្ធផលវិភាគផ្នែកលើភេទស្រីដែលទទួលបានលទ្ធផលខ្ពស់ជាងគេលើផ្នែក "អត្តទត្ថបុគ្គល" ដែលមានតម្លៃមធ្យម ៤.៤២ និងគម្លាតស្តង់ដា ០.៤៩ តាមដោយផ្នែក "និយ័តភាពការងារ" ដែលមានតម្លៃមធ្យម ៤.០២ និងគម្លាតស្តង់ដា ០.៦៥ ស្ថិតក្នុងកម្រិតដូចនឹងភេទប្រុសដែរ។ ផ្ទុយទៅវិញ បើយើងសង្កេតមើលពីកម្រិតទាបទៅខ្ពស់ យើងឃើញថាលទ្ធផលគ្រូបង្រៀនភេទប្រុសដែលទាបជាងគេលើផ្នែក "ភាពបម្រុងប្រយ័ត្ន" ដែលមានតម្លៃមធ្យម ៣.៦៧ និងគម្លាតស្តង់ដា ០.៧៣ តាមដោយផ្នែក "ឧត្តមគតិការងារ" ដែលមានតម្លៃមធ្យម ៣.៨៨ និងគម្លាតស្តង់ដា ០.៥០។ ចំណែកឯលទ្ធផលវិភាគគ្រូបង្រៀនផ្នែកលើភេទស្រី ដែលទាបជាងគេគឺផ្នែក "ឧត្តមគតិការងារ" ដែលមានតម្លៃមធ្យម ៣.៦២ និងគម្លាតស្តង់ដា ០.៦០ តាមដោយផ្នែក "មនុស្សធម៌ការងារ" ដែលមានតម្លៃមធ្យម ៣.៧០ និងគម្លាតស្តង់ដា ០.៧៤។

យើងអាចទាញបានថាលទ្ធផលវិភាគគ្រូបង្រៀនដោយប្រៀបធៀបតាមភេទប្រុស និងស្រី ឃើញថាលទ្ធផលវិភាគតាមភេទប្រុសខ្ពស់ជាង ភេទស្រី។

តារាងទី៤.៩- តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង ៥ ដោយបែងចែកតាមអាយុ (N=២២៧)

| ល.រ | ឥរិយាបថ ពលរដ្ឋសកល ក្នុងអង្គភាព | ក្រោម ៣០ (N=២៥) | | | ៣០-៤៥ (N=១៣៤) | | | ច្រើនជាង ៤៥(N=៦៨) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | M | S.D. | អត្ថន័យ | M | S.D. | អត្ថន័យ | M | S.D. | អត្ថន័យ |
| ១- | ឧត្តមគតិការងារ | ៣.៧៤ | ០.៦៩៤ | ខ្ពស់ | ៣.៧៧ | ០.៥៦០ | ខ្ពស់ | ៣.៧៨ | ០.៥១៣ | ខ្ពស់ |
| ២- | អត្តទត្តបុគ្គល | ៤.៤៥ | ០.៣៨៩ | ខ្ពស់ | ៤.៣៧ | ០.៤៩៦ | ខ្ពស់ | ៤.៣៩ | ០.៥៨៣ | ខ្ពស់ |
| ៣- | និយ័តភាពការងារ | ៣.៨២ | ០.៦៣៥ | ខ្ពស់ | ៤.១៣ | ០.៥៦៥ | ខ្ពស់ | ៤.១៥ | ០.៦១៧ | ខ្ពស់ |
| ៤- | ភាពបម្រុងប្រយ័ត្ន | ៣.១៤ | ០.៣៧៣ | មធ្យម | ៣.៧៨ | ០.៧៧០ | ខ្ពស់ | ៣.៨៦ | ០.៧៩៥ | ខ្ពស់ |
| ៥- | មនុស្សធម៌ការងារ | ៤.២៦ | ១.០០១ | ខ្ពស់ | ៣.៩០ | ០.៧៩៥ | ខ្ពស់ | ៣.៨៣ | ០.៧៣៩ | ខ្ពស់ |
| | សរុប | ៣.៨៨ | ០.៥៤៤ | ខ្ពស់ | ៣.៩៩ | ០.៤៣៧ | ខ្ពស់ | ៤.០០ | ០.៤៤៥ | ខ្ពស់ |

តាមតារាងខាងលើ លទ្ធផលបង្ហាញថា ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញដោយបែងចែកតាមកម្រិតអាយុ ស្ថិតក្នុងកម្រិតខ្ពស់។ បើយើងធ្វើការប្រៀបធៀបតាមកម្រិតអាយុរបស់គ្រូបង្រៀន យើងសង្កេតឃើញថាគ្រូបង្រៀននៅអាយុ៤៥ឆ្នាំឡើងទទួលបានលទ្ធផលកម្រិតខ្ពស់ជាងគេ ដោយមានតម្លៃមធ្យម ៤.០០ និងគម្លាតស្តង់ដា ០.៤៤ តាមដោយកម្រិតអាយុ ៣០ដល់៤៥ ដែលមានតម្លៃមធ្យម ៣.៩៩ និងគម្លាតស្តង់ដា ០.៤៣ ចំណែកឯកម្រិតអាយុក្រោម ៣០ឆ្នាំ ទទួលបានលទ្ធផលទាបជាងគេដោយមានតម្លៃមធ្យម ៣.៨៨ និង និងគម្លាតស្តង់ដា ០.៥៤។

បើយើងសង្កេតមើលទៅតាមផ្នែកទាំង៥ លទ្ធផលទទួលបានតាមកម្រិតអាយុខ្ពស់ជាងគេនៅលើផ្នែកទី២ "អត្តទត្តបុគ្គល" ដូចគ្នាទាំង៣កម្រិតអាយុ ដែលកម្រិតអាយុក្រោម ៣០ឆ្នាំ មានតម្លៃមធ្យម ៤.៤៥ និងគម្លាតស្តង់ដា ០.៣៨ កម្រិតអាយុ៣០ដល់៤៥ មានតម្លៃមធ្យម ៤.៣៧ និងគម្លាតស្តង់ដា ០.៤៩ និងកម្រិត

អាយុលើសពី៤៥ឆ្នាំ ដែលមានតម្លៃមធ្យម ៣.៣៩ និងគម្លាតស្តង់ដា ០.៥៨។ ចំណែកលទ្ធផលទទួលបានទាបជាងគេលើកម្រិតអាយុ ក្រោម៣០ឆ្នាំគឺលើផ្នែកទី៤ "ភាពបម្រុងប្រយ័ត្ន" ដែលមានតម្លៃមធ្យម ៣.១៤ និងគម្លាតស្តង់ដា ០.៣៧ តាមដោយផ្នែកទី១ "ឧត្តមគតិការងារ" ដែលមានតម្លៃមធ្យម ៣.៧៤ និងគម្លាតស្តង់ដា ០.៦៩។ លទ្ធផលទាបជាងគេសម្រាប់កម្រិតអាយុ ៣០ដល់៤៥ឆ្នាំលើផ្នែកទី១ "ឧត្តមការងារ" ដែលមានតម្លៃមធ្យម ៣.៧៧ និងគម្លាតស្តង់ដា ០.៥៦ តាមដោយផ្នែកទី៤ "ភាពបម្រុងប្រយ័ត្ន" ដែលមានតម្លៃមធ្យម ៣.៧៨ និងគម្លាតស្តង់ដា ០.៧៧។ លទ្ធផលទាបជាងគេសម្រាប់កម្រិតអាយុលើសពី៤៥ឆ្នាំលើផ្នែកទី១ "ឧត្តមគតិការងារ" ដែលមានតម្លៃមធ្យម ៣.៧៨ និងគម្លាតស្តង់ដា ០.៥១ តាមដោយផ្នែកទី៥ "មនុស្សធម៌ការងារ" ដែលមានតម្លៃមធ្យម ៣.៨៣ និងគម្លាតស្តង់ដា ០.៧៣។

យើងអាចសរុបបានថា លទ្ធផលវិភាគដោយប្រៀបធៀបតាមកម្រិតអាយុ ដែលលទ្ធផលខ្ពស់ជាងគេគឺស្ថិតក្នុងកម្រិតអាយុខ្ពស់ជាង៤៥ឆ្នាំ តាមដោយកម្រិតអាយុ៣០ដល់៤៥ឆ្នាំ និងទាបជាងគេគឺកម្រិតអាយុក្រោម៣០ឆ្នាំ។

**តារាងទី៤.១០- តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង ៥ ដោយបែងចែកតាមគុណវុឌ្ឍិ (N= ២២៧)**

| ល.រ | ឥរិយាបថ ពលរដ្ឋសកល ក្នុងអង្គភាព | ទាបជាងបរិញ្ញាបត្រ (N=១៤៣) | | | បរិញ្ញាបត្រ (N=៣៩) | | | ខ្ពស់ជាងបរិញ្ញាបត្រ (N=៤៥) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | M | S.D. | អត្ថន័យ | M | S.D. | អត្ថន័យ | M | S.D. | អត្ថន័យ |
| ១- | ឧត្តមគតិការងារ | ៣.៨០ | ០.៥៥២ | ខ្ពស់ | ៣.៧៦ | ០.៥៧៧ | ខ្ពស់ | ៣.៧៩ | ០.៥១៥ | ខ្ពស់ |
| ២- | អត្តទត្តបុគ្គល | ៤.៤៨ | ០.៤៦២ | ខ្ពស់ | ៤.៣៧ | ០.៥១៦ | ខ្ពស់ | ៤.៣៣ | ០.៥៥១ | ខ្ពស់ |
| ៣- | និយ័តភាពការងារ | ៤.១៥ | ០.៥៥៩ | ខ្ពស់ | ៤.១០ | ០.៦១៥ | ខ្ពស់ | ៤.០៦ | ០.៥៦៧ | ខ្ពស់ |
| ៤- | ភាពបម្រុងប្រយ័ត្ន | ៣.៦១ | ០.៧៦៣ | ខ្ពស់ | ៣.៧៦ | ០.៧៥៤ | ខ្ពស់ | ៣.៧៨ | ០.៨៥១ | ខ្ពស់ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៥- | មនុស្សធម៌ការងារ | ៣.៩៣ | ០.៨៨៣ | ខ្ពស់ | ៣.៩៨ | ០.៨៣០ | ខ្ពស់ | ៣.៨៥ | ០.៦៤៥ | ខ្ពស់ |
| | **សរុប** | **៤.០០** | **០.៤៧៥** | **ខ្ពស់** | **៣.៩៩** | **០.៤៥៣** | **ខ្ពស់** | **៣.៩៦** | **០.៤២៧** | **ខ្ពស់** |

តាមរយៈលទ្ធផលវិភាគក្នុងតារាងខាងលើ ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមកម្រិតគុណវុឌ្ឍិស្ថិតក្នុងកម្រិតខ្ពស់។ បើយើងធ្វើការប្រៀបធៀបតាមកម្រិតគុណវុឌ្ឍិរបស់គ្រូបង្រៀន យើងសង្កេតឃើញថា គ្រូបង្រៀនក្នុងកម្រិតទាបជាងបរិញ្ញាបត្រទទួលបានលទ្ធផលខ្ពស់ជាងគេដោយមានតម្លៃមធ្យម ៤.០០ និងគម្លាតស្តង់ដា ០.៤៧ តាមដោយកម្រិតបរិញ្ញាបត្រដែលមានតម្លៃមធ្យម ៣.៩៩ និងគម្លាតស្តង់ដា ០.៤៥ និងកម្រិតខ្ពស់ជាងបរិញ្ញាបត្រដោយមានតម្លៃមធ្យម ៣.៩៦ និងគម្លាតស្តង់ដា ០.៤២។

បើយើងសង្កេតមើលទៅលើផ្នែកទាំង៥ លទ្ធផលទទួលបានខ្ពស់ជាងគេគឺនៅផ្នែកទី២ "អត្តទត្តបុគ្គល" ដូចគ្នាទាំង៣កម្រិតគុណវុឌ្ឍិ ដែលកម្រិតទាបជាងបរិញ្ញាបត្រមានតម្លៃមធ្យម ៤.៤៨ គម្លាតស្តង់ដា ០.៤៦ តាមដោយកម្រិតបរិញ្ញាបត្រមានតម្លៃមធ្យម ៤.៣៧ និងគម្លាតស្តង់ដា ០.៥១ និងកម្រិតខ្ពស់ជាងបរិញ្ញាបត្រដែលមានតម្លៃមធ្យម ៤.៣៣ និងគម្លាតស្តង់ដា ០.៥៥។ ចំណែកឯលទ្ធផលទាបជាងគេគឺផ្នែកទី៤ "ភាពបម្រុងប្រយ័ត្ន" ដូចគ្នាគ្រប់កម្រិតគុណវុឌ្ឍិ ដែលកម្រិតទាបជាងបរិញ្ញាបត្រមានតម្លៃមធ្យម ៣.៦១ គម្លាតស្តង់ដា ០.៧៦ តាមដោយកម្រិតបរិញ្ញាបត្រមានតម្លៃមធ្យម ៣.៧៦ និងគម្លាតស្តង់ដា ០.៧៥ និងកម្រិតខ្ពស់ជាងបរិញ្ញាបត្រមានតម្លៃមធ្យម ៣.៧៨ និងគម្លាតស្តង់ដា ០.៨៥។

យើងអាចសរុបបានថា លទ្ធផលវិភាគតាមកម្រិតគុណវុឌ្ឍិរបស់គ្រូបង្រៀន លទ្ធផលខ្ពស់ជាងគេស្ថិតក្នុងកម្រិតទាបជាងបរិញ្ញាបត្រ តាមដោយកម្រិតបរិញ្ញាបត្រ និងលទ្ធផលទាបជាងគេគឺកម្រិតខ្ពស់ជាងបរិញ្ញាបត្រ។

**តារាងទី៤.១១- តម្លៃមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់ឥរិយាបថភាពជាពលរដ្ឋក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនតាមផ្នែកទាំង ៥ ដោយបែងចែកតាមបទពិសោធន៍ការបង្រៀន (N= ២២៧)**

| ល.រ | ឥរិយាបថពលរដ្ឋសកលក្នុងអង្គភាព | ក្រោម ៥ឆ្នាំ (N=២៥) | | | ៥-១០ឆ្នាំ (N=១៥៨) | | | ច្រើនជាង១០ឆ្នាំ(N=៤៤) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | M | S.D. | អត្ថន័យ | M | S.D. | អត្ថន័យ | M | S.D. | អត្ថន័យ |
| ១- | ឧត្តមគតិការងារ | ៣.៥៩ | ០.៨០៣ | ខ្ពស់ | ៣.៨៥ | ០.៥៥៦ | ខ្ពស់ | ៣.៧៨ | ០.៥១១ | ខ្ពស់ |
| ២- | អត្តទត្តបុគ្គល | ៤.៣៨ | ០.៤២៨ | ខ្ពស់ | ៤.៥០ | ០.៣៥៧ | ខ្ពស់បំផុត | ៤.៣៦ | ០.៥៥៧ | ខ្ពស់ |
| ៣- | និយ័តភាពការងារ | ៣.៧២ | ០.៦៨៨ | ខ្ពស់ | ៤.០៣ | ០.៤៩២ | ខ្ពស់ | ៤.១៨ | ០.៥៨២ | ខ្ពស់ |
| ៤- | ភាពបម្រុងប្រយ័ត្ន | ៣.១៨ | ០.៦០៣ | មធ្យម | ៣.៣៩ | ០.៥២៨ | មធ្យម | ៣.៩១ | ០.៧៨៣ | ខ្ពស់ |
| ៥- | មនុស្សធម៌ការងារ | ៤.០១ | ១.០៧០ | ខ្ពស់ | ៤.២៨ | ០.៩៥៤ | ខ្ពស់ | ៣.៨០ | ០.៦៨៤ | ខ្ពស់ |
| | **សរុប** | **៣.៧៨** | **០.៦១៦** | **ខ្ពស់** | **៤.០១** | **០.៣៩០** | **ខ្ពស់** | **៤.០១** | **០.៤៣២** | **ខ្ពស់** |

តាមរយៈតារាងខាងលើ លទ្ធផលវិភាគឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀន ក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមបទពិសោធន៍បង្រៀនស្ថិតក្នុងកម្រិតខ្ពស់។ បើយើងធ្វើការប្រៀបធៀបដោយបែងចែកតាមចំនួនឆ្នាំនៃការប្រកបអាជីពជាគ្រូបង្រៀន យើងឃើញថាគ្រូបង្រៀនដែលមានបទពិសោធន៍ ៥ទៅ១០ឆ្នាំ ទទួលបានលទ្ធផលខ្ពស់ជាងគេដោយមានតម្លៃមធ្យម ៤.០១ និងគម្លាតស្តង់ដា ០.៣៩ តាមដោយគ្រូបង្រៀនដែលមានបទពិសោធន៍លើសពី១០ឆ្នាំ ដែលមានតម្លៃមធ្យម ៤.០១ និងគម្លាតស្តង់ដា ០.៤៣ និងគ្រូបង្រៀនដែលមានបទពិសោធន៍ក្រោម៥ឆ្នាំ ដែលមានតម្លៃមធ្យម ៣.៧៨ និងគម្លាតស្តង់ដា ០.៦១។

បើយើងសង្កេតទៅមើលទាំង៥ផ្នែក លទ្ធផលខ្ពស់ជាងគឺនៅលើផ្នែកទី២ "អត្តទត្តបុគ្គល" ដូចគ្នា ដែលរៀបតាមកម្រិតខ្ពស់គឺ គ្រូមានបទពិសោធន៍បង្រៀន៥ទៅ១០ឆ្នាំ ដែលមានតម្លៃមធ្យម ៤.៥០ និងគម្លាតស្តង់ដា ០.៣៥ តាមដោយគ្រូមានបទពិសោធន៍បង្រៀនក្រោម៥ឆ្នាំ ដែលមានតម្លៃមធ្យម ៤.៣៨ និងគម្លាតស្តង់

ជា ០.៤២ និងទាបជាងគេគឺគ្រូមានបទពិសោធន៍បង្រៀនលើសពី១០ឆ្នាំ ដែលមានតម្លៃមធ្យម ៤.៣៦ និងគម្លាតស្តង់ដា ០.៥៥។ ចំណែកឯលទ្ធផលទាបជាងគេគឺនៅលើផ្នែកទាំង៥ ដោយគ្រូបង្រៀនមានបទពិសោធន៍ក្រោម៥ឆ្នាំ គឺនៅលើផ្នែកទី៤ "ភាពបម្រុងប្រយ័ត្ន" ដែលមានតម្លៃមធ្យម ៣.១៨ និងគម្លាតស្តង់ដា ០.៦០ តាមដោយផ្នែកទី១ "ឧត្តមគតិការងារ" ដែលមានតម្លៃមធ្យម ៣.៥៩ និងគម្លាតស្តង់ដា ០.៨០។ ចំណែកគ្រូមានបទពិសោធន៍បង្រៀន ៥ទៅ១០ឆ្នាំលទ្ធផលទាបជាងគេគឺនៅលើផ្នែកទី៤ "ភាពបម្រុងប្រយ័ត្ន" ដែលមានតម្លៃមធ្យម ៣.៣៩ និងគម្លាតស្តង់ដា ០.៥២ តាមដោយផ្នែកទី១ "ឧត្តមគតិការងារ" ដែលមានតម្លៃមធ្យម ៣.៨៥ និងគម្លាតស្តង់ដា ០.៨៥។ ឯគ្រូមានបទពិសោធន៍ការងារលើសពី ១០ឆ្នាំលទ្ធផលទាបជាងគេគឺស្ថិតលើផ្នែកទី១ "ឧត្តមគតិការងារ" ដែលមានតម្លៃមធ្យម ៣.៧៨ និងគម្លាតស្តង់ដា ០.៥១។

សរុបមក លទ្ធផលវិភាគដោយបែងចែកតាមបទពិសោធន៍ការបង្រៀនគឺលទ្ធផលខ្ពស់ជាងគេគឺគ្រូបង្រៀនដែលមានបទពិសោធន៍ ៥ទៅ១០ឆ្នាំ តាមដោយគ្រូបង្រៀនដែលមានបទពិសោធន៍លើសពី១០ឆ្នាំ និងលទ្ធផលទាបជាងគេគឺគ្រូបង្រៀនដែលមានបទពិសោធន៍ទាបជាង៥ឆ្នាំ។

### ៤.១.២- លទ្ធផលការស្រាវជ្រាវទិន្នន័យផ្នែកទី២

**តារាងទី៤.១២ ការប្រៀបធៀបភាពខុសគ្នា និងដូចគ្នានៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមភេទ (N=២២៧)**

| ភេទ | | ប្រុស | | ស្រី | | t | p-value |
|---|---|---|---|---|---|---|---|
| | | M | S.D. | M | S.D. | | |
| ១- | ឧត្តមគតិការងារ | ៣.៨៨ | ០.៥០៦ | ៣.៦២ | ០.៦០១ | ២.៨៧ | ០.៩២ |
| ២- | អត្តទត្តបុគ្គល | ៤.៣៧ | ០.៥២៤ | ៤.៤២ | ០.៤៩៧ | ០.១១ | ០.៧៤១ |
| ៣- | និយ័តភាពការងារ | ៤.១៦ | ០.៥៤៤ | ៤.០២ | ០.៦៥៥ | ៧.៣៦ | ០.០០៧ |
| ៤- | ភាពបម្រុងប្រយ័ត្ន | ៣.៦៧ | ០.៧៣៨ | ៣.៨២ | ០.៨១៥ | ១.៥២ | ០.២១៨ |
| ៥- | មនុស្សធម៌ការងារ | ៤.០៨ | ០.៨២៣ | ៣.៧០ | ០.៧៤១ | ២.៨៩ | ០.០៨៥ |

តាមតារាងខាងលើ ការប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមភេទលទ្ធផលការសិក្សាស្រាវជ្រាវបង្ហាញឱ្យឃើញថាផ្នែក និយ័តភាពការងារ មានភាពខុសគ្នាផ្នែកស្ថិតិយ៉ាងមានន័យសំខាន់ក្នុងកម្រិត ០.០០១ ចំណែកឯផ្នែកទាំង៤ដទៃទៀតពុំមានភាពខុសគ្នានោះទេ។

**តារាងទី៤.១៣ ការប្រៀបធៀបភាពខុសគ្នា និងដូចគ្នានៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមអាយុ (N=២២៧)**

| ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព | df | SS | MS | F | p-value |
|---|---|---|---|---|---|
| **១- ឧត្តមគតិការងារ** | | | | | |
| វាងក្រុម | ២ | ០.០២៤ | ០.០១២ | **០.០៣៨** | ០.៩៦៣ |
| ខាងក្នុងក្រុម | ២២៤ | ៧០.៨៨៧ | ០.៣១៦ | | |
| **សរុប** | **២២៦** | **៧០.៩១១** | | | |
| **២- អត្តទត្តបុគ្គល** | | | | | |
| រវាងក្រុម | ២ | ០.១១៦ | ០.០៥៨ | ០.២២០ | ០.៨០២ |
| ខាងក្នុងក្រុម | ២២៤ | ៥៩.១៧៤ | ០.២៦៤ | | |
| **សរុប** | **២២៦** | **៥៩.២៩០** | | | |
| **៣- និយ័តភាពការងារ** | | | | | |
| រវាងក្រុម | ២ | ២.៣២៩ | ១.១៦៤ | ៣.៣៦៤ | ០.០០០ |
| ខាងក្នុងក្រុម | ២២៤ | ៧៧.៥៣៩ | ០.៣៤៦ | | |
| **សរុប** | **២២៦** | **៧៩.៨៦៨** | | | |
| **៤- ភាពបម្រុងប្រយ័ត្ន** | | | | | |
| រវាងក្រុម | ២ | ១០.៣០៤ | ៥.១៥២ | **៩.២៧៣** | ០.០៧០ |
| ខាងក្នុងក្រុម | ២២៤ | ១២៤.៤៥១ | ០.៥៥៦ | | |

| | | | | | |
|---|---|---|---|---|---|
| សរុប | ២២៦ | ១៣៤.៧៥៥ | | | |
| **៥- មនុស្សធម៌ការងារ** | | | | | |
| វាងក្រុម | ២ | ៣.៤៧៦ | ១.៧៣៨ | ២.៦៩០ | ០.៤៨១ |
| ខាងក្នុងក្រុម | ២២៤ | ១៤៤.៧៥០ | ០.៦៤៦ | | |
| **សរុប** | **២២៦** | **១៤៨.២២៦** | | | |

តាមតារាងខាងលើ ការប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមអាយុ លទ្ធផលការសិក្សាស្រាវជ្រាវបង្ហាញឱ្យឃើញថាផ្នែកទី ៣ "និយ័តភាពការងារ" មានភាពខុសគ្នាផ្នែកស្ថិតិយ៉ាងមានសារៈសំខាន់ក្នុងកម្រិត ០.០០១ រីឯផ្នែកទាំង៤ ផ្សេងទៀតមិនខុសគ្នាទេ។

**តារាងទី៤.១៤ ការប្រៀបធៀបភាពខុសគ្នា និងដូចគ្នានៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមគុណវុឌ្ឍិ (N=២២៧)**

| ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព | df | SS | MS | F | p-value |
|---|---|---|---|---|---|
| **១- ឧត្តមគតិការងារ** | | | | | |
| វាងក្រុម | ២ | ០.០៨៧ | ០.០៤៤ | **០.១៣៨** | ០.៨៧១ |
| ខាងក្នុងក្រុម | ២២៤ | ៧០.៨២៣ | ០.៣១៦ | | |
| **សរុប** | **២២៦** | **៧០.៩១១** | | | |
| **២- អត្តទត្តបុគ្គល** | | | | | |
| វាងក្រុម | ២ | ០.៥២២ | ០.២៦១ | ០.៩៩៥ | ០.៣៧១ |
| ខាងក្នុងក្រុម | ២២៤ | ៥៨.៧៦៨ | ០.២៦២ | | |
| **សរុប** | **២២៦** | **៥៩.២៩០** | | | |
| **៣- និយ័តភាពការងារ** | | | | | |
| វាងក្រុម | ២ | ០.១៩០ | ០.០៩៥ | ០.២៦៦ | ០.៧៦៦ |

| | | | | | |
|---|---|---|---|---|---|
| ខាងក្នុងក្រុម | ២២៤ | ៧៩.៦៧៨ | ០.៣៥៦ | | |
| **សរុប** | **២២៦** | **៧៩.៨៦៨** | | | |
| **៤- ភាពបម្រុងប្រយ័ត្ន** | | | | | |
| រវាងក្រុម | ២ | ០.៨៦៧ | ០.៤៣៣ | **០.៧២៥** | ០.៤៨៥ |
| ខាងក្នុងក្រុម | ២២៤ | ១៣៣.៨៨៨ | ០.៥៩៨ | | |
| សរុប | ២២៦ | ១៣៤.៧៥៥ | | | |
| **៥- មនុស្សធម៌ការងារ** | | | | | |
| រវាងក្រុម | ២ | ០.២៤៥ | ០.១២២ | ០.១៨៥ | ០.៨៣១ |
| ខាងក្នុងក្រុម | ២២៤ | ១៤៧.៩៨២ | ០.៦៦១ | | |
| **សរុប** | **២២៦** | **១៤៨.២២៦** | | | |

តាមតារាងខាងលើ ការប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមកម្រិតគុណវុឌ្ឍិពុំមានភាពខុសគ្នាផ្នែកស្ថិតិនោះទេ។

**តារាងទី៤.១៥ ការប្រៀបធៀបភាពខុសគ្នា និងដូចគ្នានៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមបទពិសោធន៍បង្រៀន (N=២២៧)**

| ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព | df | SS | MS | F | p-value |
|---|---|---|---|---|---|
| **១- ឧត្តមគតិការងារ** | | | | | |
| រវាងក្រុម | ២ | ១.០៨៧ | ០.៥៤៤ | **១.៧៤៤** | ០.១៧៧ |
| ខាងក្នុងក្រុម | ២២៤ | ៦៩.៨២៤ | ០.៣១២ | | |
| **សរុប** | **២២៦** | **៧០.៩១១** | | | |
| **២- អត្តទត្តបុគ្គល** | | | | | |
| រវាងក្រុម | ២ | ០.៦៣៧ | ០.៣១៨ | ១.២១៦ | ០.២៩៨ |
| ខាងក្នុងក្រុម | ២២៤ | ៥៨.៦៥៣ | ០.២៦២ | | |

| | | | | | | |
|---|---|---|---|---|---|---|
| | **សរុប** | **២២៦** | **៥៩.២៩០** | | | |
| **៣-** | **និយ័តភាពការងារ** | | | | | |
| | រវាងក្រុម | ២ | ៤.៩១៥ | ២.៤៥៨ | ៧.៣៤៥ | 0.0១ |
| | ខាងក្នុងក្រុម | ២២៤ | ៧៤.៩៥៣ | 0.៣៣៥ | | |
| | **សរុប** | **២២៦** | **៧៩.៨៦៨** | | | |
| **៤-** | **ភាពបម្រុងប្រយ័ត្ន** | | | | | |
| | រវាងក្រុម | ២ | ១៧.៨៥៦ | ៨.៩២៨ | **១៧.១០៨** | 0.000 |
| | ខាងក្នុងក្រុម | ២២៤ | ១១៦.៨៩៩ | 0.៥២២ | | |
| | សរុប | ២២៦ | ១៣៤.៧៥៥ | | | |
| **៥-** | **មនុស្សធម៌ការងារ** | | | | | |
| | រវាងក្រុម | ២ | ៧.៩៤0 | ៣.៩៧0 | ៦.៣៣៩ | 0.0២ |
| | ខាងក្នុងក្រុម | ២២៤ | ១៤0.២២៦ | 0.៦២៦ | | |
| | **សរុប** | **២២៦** | **៤៦.0៦២** | | | |

តាមតារាងខាងលើ ការប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាមបទពិសោធន៍បង្រៀន លទ្ធផលការស្រាវជ្រាវបង្ហាញឱ្យឃើញថាផ្នែកទី៣ "និយ័តភាពការងារ" ផ្នែកទី៤ "ភាពបម្រុងប្រយ័ត្ន" មានភាពខុសគ្នាផ្នែកស្ថិតិយ៉ាងមានសារៈសំខាន់ក្នុងកម្រិត 0.0១ ចំណែកឯផ្នែកទី៥ "មនុស្សធម៌ការងារ" មានភាពខុសគ្នាផ្នែកស្ថិតិយ៉ាងមានសារៈសំខាន់ក្នុងកម្រិត 0.0៥ រីឯផ្នែកទី១ "ឧត្តមគតិការងារ" និងផ្នែកទី២ "អត្តទត្តបុគ្គល" ពុំមានភាពខុសគ្នាទេ។

## ៤.២- ការពិភាក្សាលទ្ធផលស្រាវជ្រាវ

### ៤.២.១- ទស្សនៈគ្រូបង្រៀនលើឥរិយាបថភាពជាពលរដ្ឋសកល

ចំពោះទស្សនៈគ្រូបង្រៀនលើឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀននៅកម្រិតវិទ្យាល័យ នៅរាជធានីភ្នំពេញ ដែលអ្នកស្រាវជ្រាវបានវិភាគចេញជាទិន្នន័យមក បានបង្ហាញឱ្យឃើញថាលទ្ធ

ផលដែលទទួលបានជារួមគឺស្ថិតក្នុងកម្រិតខ្ពស់ នេះសបញ្ជាក់ឱ្យឃើញថា គ្រូបង្រៀនគឺបានប្រព្រឹត្តឥរិយាបថបានល្អនៅក្នុងអង្គភាពរបស់ខ្លួន សមស្របទៅនឹងស្តង់ដារសេកលលោកផងដែរ ។ គ្រូបង្រៀននៅកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ បានប្រព្រឹត្តឥរិយាបថបានល្អនៅក្នុងអង្គភាពរបស់ពួកគាត់ ដោយពួកគាត់ការមានឧត្តមគតិខ្ពស់ក្នុងការប្រកបការងារបង្រៀន តាមរយៈការអនុវត្តការបង្រៀនគ្រប់ចំនួនម៉ោងកំណត់តាមនិយាមត្រឹមត្រូវ មានស្មារតីទទួលខុសត្រូវខ្ពស់ចំពោះកិច្ចការខ្លួន និងថែមទាំងគោរពបាននូវរាល់បទបញ្ជាផ្សេងៗរបស់សាលាបានយ៉ាងខ្ជាប់ខ្ជួនទៀតផង។ មិនតែប៉ុណ្ណោះ លោកគ្រូអ្នកគ្រូមិនបានបង្ហាញចេញឡើងនូវភាពអាត្មានិយមណាមួយក្នុងការងារនោះទេ ដោយលោកតែងតែផ្តោតទៅលើប្រយោជន៍រួម ដំណោះស្រាយជាធំ ហើយថែមទាំងបានចូលរួមចំណែកជួយសាលានូវរាល់កិច្ចការនានាជាច្រើនមិនថាធំឬតូចផងដែរ។ ទង្វើដែលបង្ហាញចេញនៅក្នុងអង្គភាពរបស់បុគ្គលិកទាំងឡាយ គឺពិតជាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើបរិយាកាសការងារ និងការសម្រេចផែនការរួមរបស់អង្គភាពទាំងមូល ហើយការផ្លាស់ប្តូរអាកប្បកិរិយានិងឥរិយាបថរបស់បុគ្គលិកគឺសំដៅបង្កើនប្រសិទ្ធភាពការងារក្នុងពេលបច្ចុប្បន្ននិងពេលអនាគត (គោលនយោបាយស្តីពីធនធានមនុស្សអប់រំ)។ យ៉ាងណាមិញបច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានកំពុងតែធ្វើដំណើរនៅលើផ្លូវរួមដ៏ធំមួយជាមួយបណ្តាប្រទេសមួយចំនួនទៀតក្នុងសកលលោក ដោយមានគោលដៅត្រឹមឆ្នាំ ២០៣០ ធានាយ៉ាងណាឱ្យអ្នកសិក្សាគ្រប់រូបទទួលបានចំណេះដឹង និងជំនាញដែលចាំបាច់ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងបែបផែននៃការរស់នៅប្រកបដោយចីរភាព សិទ្ធមនុស្ស សមភាពយេនឌ័រ ការលើកកម្ពស់វប្បធម៌សន្តិភាព និងអហិង្សា ភាពជាប្រជាពលរដ្ឋសកល និងការយល់ពីលក្ខណៈចម្រុះរបស់វប្បធម៌ និងការរួមចំណែកនៃវប្បធម៌ចំពោះការអភិវឌ្ឍដោយចីរភាព (ផែនទីបង្ហាញផ្លូវ ចំណុចដៅ SDG ៤.៧)។ ទាំងអស់នេះអាចប្រព្រឹត្តទៅបានដោយជោគជ័យ ឬមិនបានជោគជ័យគឺអាស្រ័យទៅលើធនធានមនុស្ស។ ការប្រើប្រាស់ធនធានមនុស្សឱ្យអស់លទ្ធភាពមានសារៈសំខាន់ណាស់ ដែលជាកម្លាំងចលករមិនអាចខ្វះបានក្នុងការធ្វើឱ្យសម្រេចបំណងប្រាថ្នាខាងលើ និងអាចធ្វើឱ្យអង្គភាពទាំងមូលរីកចម្រើនប្រកបដោយចីរភាពផងដែរ។ ដើម្បីអាចសម្របខ្លួន

ទៅនឹងការវិវត្តរបស់ពិភពលោកនិងតំបន់ ក្នុងន័យបង្កើនការប្រកួតប្រជែង គ្រូបង្រៀនមានភារៈកិច្ចសំខាន់ក្នុងការជុសខាត់ធនធានមនុស្សជំនាន់ថ្មីឱ្យមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ឈរលើឆាកអន្តរជាតិ។ ផ្ទុយទៅវិញ ប្រសិនបើ គ្រូបង្រៀនមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ និងមិនទាន់បានដើរតាមស្តង់ដារសកលនៅឡើយនោះទេ យើងក៏ពុំអាចផលិតចេញនូវធនធានដែលមានសមត្ថភាពក្នុងការប្រកួតប្រជែងជាលក្ខណៈសកលលោកផងដែរ។ ជារួម ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិ គឺអាស្រ័យលើធនធានមនុស្ស ចំណែកធនធានមនុស្សដែលល្អក៏កើតចេញបានពីការជុសខាត់នៅសាលារៀន ហើយសាលារៀនដែលបណ្តុះបានធនធានមនុស្សដែលមានសមត្ថភាពនោះគឺអាស្រ័យទៅលើគ្រូបង្រៀន។ ដូចនេះឥរិយាបថគ្រូបង្រៀនពិតជាជះឥទ្ធិពលយ៉ាងធំធេងទៅលើប្រទេសជាតិទាំងមូល។ ចំណែកឯគ្រូបង្រៀនដែលប្រព្រឹត្តបានល្អនូវឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពសាលារៀននោះ គឺពិតជារួមចំណែកយ៉ាងធំធេងក្នុងការផលិតធនធានមនុស្ស ក៏ដូចជារួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូលផងដែរ។

គ្រូបង្រៀននៅកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ បានប្រព្រឹត្តនូវឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពបានយ៉ាងល្អ តាមរយៈលទ្ធផលស្រាវជ្រាវខាងលើ។ អ្នកសិក្សាស្រាវជ្រាវបានលើកយក ២៥ចំណុចដើម្បីវាយតម្លៃឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀន ដោយប្រើប្រាស់ទ្រឹស្តីរបស់លោកប៊ែតមេន និងអូហ្គិន រួមជាមួយនឹងគោលការណ៍វាយតម្លៃបុគ្គលិករបស់ក្រសួងអប់រំ។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា ចំណុចដែលលោកគ្រូអ្នកគ្រូបានធ្វើល្អស្មើរគ្រប់គ្នាគឺ ការដែលមិនចាប់កំហុសអ្នកដទៃនៅកន្លែងការងារ។ អង្គភាពមួយរីកចម្រើនបាន លុះត្រាតែបុគ្គលិកប្រកៀកស្មារគ្នា តស៊ូជាមួយគ្នាក្នុងការដោះស្រាយបញ្ហានានា និងការចូលរួមជាមួយគ្នាដើម្បីប្រយោជន៍រួម។ ដូចនេះហើយ ទើបការចេះជួយគ្នា និងកែលម្អគ្នាគឺពិតជាមានសារៈសំខាន់ណាស់សម្រាប់អង្គភាព។ បុគ្គលិកក្នុងអង្គភាពចេះស្រឡាញ់រាប់អានគ្នា ចែករំលែកចំណេះដឹងដល់គ្នា ផ្តល់ជាមតិដើម្បីកែតម្រូវ និងជួយគ្នាដោះស្រាយបញ្ហាគ្នាទៅវិញទៅមក នឹងបង្កើតបាននូវបរិយាកាសការងារវិជ្ជមាន។ ផ្ទុយទៅវិញ ប្រសិនបើបុគ្គលិកប្រកាន់ខ្ជាប់នូវឥរិយាបថអវិជ្ជមានចំពោះគ្នា

ព្យាយាមយកឈ្នះចាញ់គ្នា សើចចំអកគ្នានៅពេលឃើញកំហុស ឬចាំតែចាប់កំហុសគ្នានោះ អង្គភាពនឹងមិនអាចសម្រេចការងារជោគជ័យបាននោះឡើយ ពោលគឺសាលាទាំងមូលនឹងមិនអាចបង្កើតបានបរិយាកាសរៀន និងបង្រៀនប្រកបដោយភាពរីករាយនោះទេ ហើយវានឹងធ្វើឱ្យប៉ះពាល់ដល់ដំណើរការនៃការសិក្សារបស់សិស្សផងដែរ។ ដូចនេះ លទ្ធផលនៃការសិក្សាពិតជាបញ្ជាក់ឱ្យឃើញថាគ្រូបង្រៀនកម្រិតវិទ្យាល័យ នៅរាជធានីភ្នំពេញ ពិតជាបានប្រព្រឹត្តឥរិយាបថបានល្អ ដោយមិនមានអ្នកណាម្នាក់ចាំចាប់កំហុសគ្នានោះឡើយ។

ភ្ជាប់ជាមួយការបកស្រាយខាងលើ អ្នកស្រាវជ្រាវបានបង្ហាញបន្ថែមនូវគោលគំនិតទៅលើឥរិយាបថគ្រូបង្រៀនដែលមិនចាំចាប់កំហុសគ្នាទៅវិញទៅមក ដែលអាចធ្វើឱ្យប៉ះពាល់ដល់ដំណើរការសិក្សារបស់សិស្ស ក៏ដូចជាការងាររបស់អង្គភាពទាំងមូល ដែលជាចំណុចមួយក្នុងផ្នែកអត្តទត្ថបុគ្គល។ ម្យ៉ាងទៀតផ្នែកអត្តទត្ថបុគ្គលនេះផងដែរ គឺជាផ្នែកដែលទទួលបានលទ្ធផលខ្ពស់ជាងគេក្នុងចំណោមផ្នែក៤ដទៃទៀត ហើយផ្នែកនេះផ្តោតទៅលើការមិនគិតតែពីប្រយោជន៍ផ្ទាល់ខ្លួននៅក្នុងអង្គភាព តាមរយៈឥរិយាបថបង្ហាញចេញមកក្រៅ។ ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួនគឺជាសកម្មភាពសំខាន់មួយក្នុងចំណោមសកម្មភាពមួយចំនួនទៀត ដែលអាចពង្រឹង និងពង្រីកលទ្ធផលការងារក្នុងអង្គភាព ហើយថែមទាំងបង្ហាញឱ្យឃើញជាក់ស្តែងនូវភាពជាបងប្អូនក្នុងស្ថាប័នរួមមួយផងដែរ។ នេះសបញ្ជាក់ឱ្យឃើញពីឥរិយាបថល្អរបស់គ្រូបង្រៀនយើង និងបញ្ជាក់បានអំពីបរិយាកាសការងារក្នុងអង្គភាពដែលពោរពេញទៅដោយភាពវិជ្ជមាន នឹងកំពុងតែឈានទៅដល់ភាពជោគជ័យក្នុងការបណ្តុះចេញបាននូវធនធានមានសមត្ថភាពសម្រាប់ការអភិវឌ្ឍនាពេលអនាគត។ ផ្នែកអត្តទត្ថបុគ្គលនេះក៏បានរួមបង្ហាញឱ្យឃើញពីឥរិយាបថគ្រូបង្រៀនទៅកាន់ការដោះស្រាយបញ្ហាផ្ទៃក្នុងអង្គភាពណាមួយ ហើយពួកគាត់បានកំពុងប្រព្រឹត្តទៅបានយ៉ាងល្អ ដោយគ្រូទាំងអស់សុទ្ធសឹងតែចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយរាល់បញ្ហាកើតមានឡើងក្នុងអង្គភាព ដោយមិនគិតថាជាបញ្ហាឯកជនរបស់ជនណា ឬមិនគិតថាជាកំហុសអ្នកណាឡើយ ប៉ុន្តែពួកគាត់ផ្តោតទៅលើការរកដំណោះស្រាយដើម្បីជួយគ្នាជាជាងការចាប់កំហុស និងទម្លាក់កំហុសដាក់គ្នា។ ស្ថានភាពមួយនេះបង្កើតឱ្យមានសាមគ្គីភាព ហើយសាមគ្គីភាពនេះនឹង

ជួយឱ្យកកើតនូវសមិទ្ធផលជាផ្លែផ្កាយ៉ាងច្រើនអនេក។ ឥរិយាបថបែបនេះក៏បានចូលរួមផ្សារភ្ជាប់ជាមួយនឹងការសម្រេចគោលដៅនៃការអប់រំដែលមានលក្ខណៈទូលំទូលាយ ទាមទារឱ្យតួអង្គពាក់ព័ន្ធនានាធ្វើការសហការ និងប្រាស្រ័យទាក់ទងជាមួយគ្នា។

### ៤.២.២- ការប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀន

ក្នុងការប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យ ត្រូវបានបែងចែកទៅតាមភេទ ដោយក្នុងនោះយើងធ្វើការប្រៀបធៀបទស្សនៈរបស់គ្រូភេទប្រុស និងទស្សនៈរបស់គ្រូភេទស្រី។ យោងតាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា ការគិតរបស់គ្រូបង្រៀនទាំងពីរភេទមានភាពខុសគ្នាផ្នែកស្ថិតិយ៉ាងមានន័យក្នុងកម្រិត ០.០១ សម្រាប់ផ្នែកនិយ័តភាពការងារ។ គ្រូបង្រៀនទាំងពីរភេទ មានការគិតខុសគ្នាដោយអាស្រ័យទៅលើហេតុផល និងកត្តាស្ថានភាពរៀងៗខ្លួន។ ក្នុងនោះផងដែរពួកគាត់ ពុំមានការគិតដូចគ្នាទៅលើបញ្ហាការប្រជុំដែលមិនមែនជាកាតព្វកិច្ចរបស់គាត់ ព្រោះគ្រូមួយចំនួនយល់ថាគាត់ត្រូវចាំបាច់ដឹងពីការប្រជុំដែរ ដើម្បីអាចចូលរួមជួយដោះស្រាយនូវបញ្ហាណាមួយទៅតាមសមត្ថភាពគាត់ ប៉ុន្តែគ្រូមួយចំនួនទៀតមិនបានគិតបែបនោះទេ ដោយគាត់គិតពីតួនាទីជាក់ស្តែងរបស់គាត់។ ជាងនេះទៅទៀត ក្នុងផ្នែកនេះដដែល ក៏បង្ហាញឱ្យឃើញនូវឥរិយាបថរបស់គ្រូបង្រៀនទាំងពីរភេទមានការយល់ឃើញមិនដូចគ្នាទៅលើការចូលរួមធ្វើកិច្ចការនានារបស់សាលាដែលមិនមែនជាតួនាទីខ្លួន ដោយសំអាងទៅលើការគិតរៀងៗខ្លួនស្របជាមួយនឹងការចងក្រងរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលឆ្នាំ២០១៧បានរៀបរាប់ឡើងដែរថា ការធានានូវការអប់រំបរិយាប័ន្នប្រកបដោយគុណភាព និងសមធម៌ជាកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ដោយត្រូវបំពេញទៅតាមទំនួលខុសត្រូវរៀងៗខ្លួន។ ។ គ្រូបង្រៀនភេទប្រុស និងគ្រូបង្រៀនភេទស្រីមានការគិតខុសគ្នាទៅតាមស្ថានការណ៍រៀងៗខ្លួន និងបង្ហាញចេញមកផ្សេងគ្នាទៅតាមទំនួលខុសត្រូវរៀងៗខ្លួន។

សម្រាប់ការប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញនេះដដែល ក៏ត្រូវបានធ្វើការប្រៀបធៀបទៅតាមកម្រិតអាយុផងដែរ ដោយក្នុងនោះយើងបានបែងចែកអាយុជា៣កម្រិត មានដូចជាក្រោម៣០ឆ្នាំ ចន្លោះពី៣០ដល់៤៥ឆ្នាំ និងចាប់ពី៤៥ឆ្នាំឡើង។ លទ្ធផលបានបង្ហាញឱ្យឃើញថាគ្រូបង្រៀនទាំង៣កម្រិតអាយុមានការគិតខុសគ្នាលើផ្នែកនិយ័តភាពការងារយ៉ាងមានន័យក្នុងកម្រិត ០.០១។ បញ្ជាក់បានថាគ្រូបង្រៀនកម្រិតអាយុទាំង ៣ ពុំមានការគិតដូចគ្នាទៅលើការអនុវត្តសេចក្តីប្រកាសនានារបស់សាលា ឬអនុសារណៈផ្សេងៗ និងការវិវត្តន៍ថ្មីរបស់សាលា។ អាស្រ័យទៅតាមវ័យរបស់ពួកគាត់ ការគិតនិងឥរិយាបថដែលបង្ហាញចេញសម្រាប់សកម្មភាពទាំងនោះពុំបានធ្វើឡើងដូចគ្នានោះឡើយ។ យ៉ាងណាមិញរៀងរាល់សេចក្តីប្រកាសនានាដែលសាលាបានផ្សព្វផ្សាយសម្រាប់លោកគ្រូអ្នកគ្រូ គឺតែងតែត្រូវបានយកទៅអនុវត្តយ៉ាងខ្ជាប់ខ្ជួន មិនថាលោកគ្រូអ្នកគ្រូស្ថិតក្នុងវ័យណាមួយនោះឡើយ។ ការអនុវត្តនូវគោលការណ៍ដែលដាក់ចេញពីថ្នាក់លើ មិនថាសាលារៀន ឬក្រសួងនោះឡើយជាតួនាទីរបស់បុគ្គលិកក្នុងអង្គភាពដែលត្រូវយកទៅអនុវត្ត ក្នុងន័យសម្រេចបាននូវគោលដៅរួមមួយជាមួយគ្នា។ ភាពស៊ីសង្វាក់គ្នារវាងកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល និងរបស់ក្រសួងអប់រំយុវជន និងកីឡា នឹងជានាឱ្យការអនុវត្តគោលនយោបាយបានជោគជ័យ (គោលនយោបាយស្តីពីគ្រូបង្រៀន ឆ្នាំ២០១៣)។

ស្ថិតិដដែលបានទទួលលទ្ធផលខុសគ្នាសម្រាប់ ការប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យ ដោយផ្តោតទៅលើគុណវុឌ្ឍិ។ លទ្ធផលដែលទទួលបានសម្រាប់ការប្រៀបធៀបគុណវុឌ្ឍិគ្រូបង្រៀនដែលបែងចែកជា ៣ គុណវុឌ្ឍិមានដូចជា គ្រូបង្រៀនដែលមិនទាន់បានបញ្ចប់បរិញ្ញាបត្រ គ្រូបង្រៀនបញ្ចប់បរិញ្ញាបត្រ និងគ្រូបង្រៀនដែលបានចប់លើសពីបរិញ្ញាបត្រ គឺមានភាពដូចគ្នាតាមផ្នែកស្ថិតិយ៉ាងមានន័យក្នុងកម្រិត ០.០១។ នេះបញ្ជាក់បានថា ការគិតរបស់គ្រូបង្រៀន មិនថាគុណវុឌ្ឍិស្ថិតក្នុងកម្រិតបែបណា ក៏ការយល់ឃើញនិងឥរិយាបថបង្ហាញចេញមកនោះដូចគ្នាដែរ។ គោលដៅអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ក្នុងពេលបម្រើការងាររបស់ក្រសួងអប់រំ នៅតែជាគោលដៅសំខាន់សម្រាប់គោលនយោបាយស្តីពី

គ្រូបង្រៀន។ លក្ខណៈសម្បត្តិលើសមត្ថភាពទទួលស្គាល់ជាផ្លូវការក្នុងក្របខណ្ឌអប់រំ ឬវិជ្ជាជីវៈ ដែលបញ្ជាក់ដោយសញ្ញាបត្រ ឬបរិញ្ញាបត្រ មិនវាយតម្លៃពីឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូនោះឡើយ ដោយយោងតាមលទ្ធផលប្រៀបធៀបគុណវុឌ្ឍិទាំង ៣កម្រិតបង្ហាញចេញមកថាការយល់ឃើញរបស់ពួកគាត់ពុំមានភាពខុសគ្នា។

ផ្ទុយពីការប្រៀបធៀបគុណវុឌ្ឍិគ្រូបង្រៀនទៅលើឥរិយាបថភាពជាពលរដ្ឋសកល ការប្រៀបធៀបទៅតាមបទពិសោធន៍បង្រៀនវិញគឺមានភាពខុសគ្នាលើផ្នែកស្ថិតិយ៉ាងមានន័យ ក្នុងកម្រិត 0.0១ ដល់ទៅ៣ផ្នែក។ ដោយក្នុងការប្រៀបធៀបនេះត្រូវបានបែងចែកបទពិសោធន៍គ្រូបង្រៀនជា៣កម្រិតដូចជា ក្រោម៥ឆ្នាំ ចន្លោះពី៥ទៅ១០ឆ្នាំ និងចាប់ពី១០ឆ្នាំឡើង។ ការគិតរបស់គ្រូបង្រៀនដោយផ្អែកទៅលើបទពិសោធន៍បង្រៀនមានការខុសគ្នាទៅលើផ្នែក និយ័តភាពការងារ ភាពបម្រុងប្រយ័ត្ន និងមនុស្សធម៌ការងារ។ គ្រូបង្រៀនបានប្រព្រឹត្តឥរិយាបថភាពជាពលរដ្ឋសកល និងមានការគិតផ្សេងគ្នាទៅលើការអនុវត្តសេចក្តីប្រកាស ឬអនុសារណៈនានារបស់សាលា ដោយគ្រូបង្រៀនដែលមានបទពិសោធន៍តិចគិតផ្សេង និងគ្រូបង្រៀនដែលមានបទពិសោធន៍យូរឆ្នាំមានការយល់ឃើញផ្សេង ប៉ុន្តែការអនុវត្តរបស់ពួកគាត់គឺប្រព្រឹត្តបានល្អគ្រប់ៗគ្នា។ មួយវិញទៀត ភាពបម្រុងប្រយ័ត្នចំពោះមនុស្សជុំវិញខ្លួនក៏មិនដូចគ្នាដែរ គ្រូមួយចំនួនមានការយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នមិនឱ្យសកម្មភាពឬឥរិយាបថខ្លួនប៉ះពាល់ដល់មិត្តរួមការងារ គិតថាសកម្មភាពប៉ះពាល់ទៅលើអ្នកជុំវិញខ្លួនគឺជារឿងធំដែលពួកគាត់ព្យាយាមមិនឱ្យកើតមាន។ ចំណែកគ្រូបង្រៀនតាមកម្រិតបទពិសោធន៍ផ្សេងទៀតមិនបានយល់ដូចគ្នា ដោយអាស្រ័យលើទំនាក់ទំនង មិត្តភាពជិតស្និទ្ធ និងការគិតវិជ្ជមានទៅលើមនុស្សជុំវិញខ្លួន។ ការគិតគូរពីមនុស្សជុំវិញខ្លួនជារឿងល្អបំផុត ដែលជួយឱ្យគេចចេញពីការបង្ករជម្លោះដោយអចេតនា ឬប៉ះទង្គិចផ្លូវចិត្តដោយមិនបានតាំងចិត្ត។ កម្រិតបទពិសោធន៍ក៏ធ្វើឱ្យ លោកគ្រូអ្នកគ្រូគិតខុសៗគ្នាទៅលើការជួយគ្នាពេលមិត្តរួមការងារអវត្តមាន ឬពេលឃើញមិត្តរួមការងារមានការងារច្រើន។ បូកផ្សំជាមួយនឹងឆន្ទៈ ទឹកចិត្តស្រលាញ់រាប់អានគ្នាជួយគ្នាដោះស្រាយបញ្ហា និងត្រៀមខ្លួនជានិច្ចដើម្បីយកអាសារគ្នាទៅវិញ

ទៅមក។ លោកគ្រូអ្នកគ្រូមានបទពិសោធន៍បង្រៀនតិច និងលោកគ្រូអ្នកគ្រូមានបទពិសោធន៍បង្រៀនយូរឆ្នាំ មានការគិតខុសគ្នា ប៉ុន្តែពួកគាត់បានប្រព្រឹត្តឥរិយាបថភាពជាពលរដ្ឋសកលបានល្អព្រមគ្នាដោយមិនបានធ្វើឡើយនូវសកម្មភាពពុំគប្បីណាមួយ ទោះជាការគិតរបស់ពួកគាត់ស្ថិតក្នុងកម្រិតខុសគ្នាក្តី។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និង

# សំណូមពរ

# ជំពូក៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

ក្នុងជំពូកនេះនិយាយអំពីសេចក្តីសន្និដ្ឋាន និងសំណូមពរក៏ដូចជានិយាយអំពីអនុសាសន៍មួយចំនួនពាក់ព័ន្ធទៅនឹងឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព របស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ។ ការសិក្សាអំពីឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀន មានគោលបំណងពីរសំខាន់។ (១) ស្វែងយល់ពីទស្សនៈរបស់គ្រូបង្រៀកម្រិត វិទ្យាល័យ ក្នុងរាជធានីភ្នំពេញ លើឥរិយាបថក្នុងអង្គភាព ទាំង៥ផ្នែក មានឧត្តមគតិការងារ អត្តទត្ថបុគ្គល និយ័តភាពការងារ ភាពបម្រុងប្រយ័ត្ន និងមនុស្សធម៌ការងារ។ (២) វាស់ស្ទង់ឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាម ភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍ការបង្រៀន។ ប្រជាជនដែលប្រើក្នុងការស្រាវជ្រាវនេះ គឺគ្រូបង្រៀនកម្រិតវិទ្យាល័យដែលរាប់បញ្ចូលពីថ្នាក់ទី ៧ដល់ ថ្នាក់ទី១២ នៅក្នុងរាជធានីភ្នំពេញចំនួន ២២៧នាក់ ដែលរើសចេញពីសាលាចំនួន៦ ដែលស្ថិតក្នុងខណ្ឌចំនួន៦ផ្សេងគ្នា ក្នុងនោះមាន វិទ្យាល័យឬស្សីកែវស្ថិតក្នុងខណ្ឌឬស្សីកែវ វិទ្យាល័យសម្តេចតេជោហ៊ុនសែនសំរោងស្ថិតក្នុងខណ្ឌព្រែកព្នៅ វិទ្យាល័យហ៊ុនសែនកោះដាច់ស្ថិតក្នុងខណ្ឌជ្រោយចង្វារ វិទ្យាល័យបឹងធំស្ថិតក្នុងខណ្ឌកំបូល វិទ្យាល័យច្បារអំពៅស្ថិតក្នុងខណ្ឌច្បារអំពៅ និងវិទ្យាល័យចំរើនផលស្ថិតក្នុងខណ្ឌមានជ័យ។ ស្ថិតតិដែលប្រើសម្រាប់ប្រមូលទិន្នន័យ គឺជាកម្រងសំណួរផ្នែកតី១ដែលពាក់ព័ន្ធនឹងព័ត៌មានអំពីស្ថានភាពទូទៅរបស់លោកគ្រូអ្នកគ្រូ មានដូចជា ភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍បង្រៀន។ ផ្នែកទី២ ទស្សនៈគ្រូបង្រៀនទៅលើការអនុវត្តឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព។

## ៥.១- សរុបលទ្ធផលការស្រាវជ្រាវ

ការសិក្សាអំពីឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀន មានគោលបំណងពីរសំខាន់៖ (១) ស្វែងយល់ពីទស្សនៈរបស់គ្រូបង្រៀកម្រិត វិទ្យាល័យ ក្នុងរាជធានីភ្នំពេញ លើឥរិយាបថក្នុងអង្គ

ភាព ទាំង៥ផ្នែក មានឧត្តមគតិការងារ អត្តទត្តបុគ្គល និយ័តភាពការងារ ភាពបម្រុងប្រយ័ត្ន និងមនុស្សធម៌ការងារ និង (២) វាស់ស្ទង់ឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ដោយបែងចែកតាម ភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍ការបង្រៀន។ ប្រជាជនដែលប្រើក្នុងការស្រាវជ្រាវនេះ គឺគ្រូបង្រៀនកម្រិតវិទ្យាល័យដែលរាប់បញ្ចូលពីថ្នាក់ទី ៧ដល់ ថ្នាក់ទី១២ នៅក្នុងរាជធានីភ្នំពេញចំនួន ២២៧នាក់ ដែលរើសចេញពីសាលាចំនួន៦ ដែលស្ថិតក្នុងខណ្ឌចំនួន៦ផ្សេងគ្នា ក្នុងនោះមានវិទ្យាល័យឬស្សីកែវស្ថិតក្នុងខណ្ឌឬស្សីកែវ វិទ្យាល័យសម្តេចតេជោហ៊ុនសែនសំពោងស្ថិតក្នុងខណ្ឌព្រែកព្នៅ វិទ្យាល័យហ៊ុនសែនកោះដាច់ស្ថិតក្នុងខណ្ឌជ្រោយចង្វារ វិទ្យាល័យបឹងធំស្ថិតក្នុងខណ្ឌកំបូល វិទ្យាល័យច្បារអំពៅស្ថិតក្នុងខណ្ឌច្បារអំពៅ និងវិទ្យាល័យចំរើនផលស្ថិតក្នុងខណ្ឌមានជ័យ។ ស្ថិតិដែលប្រើសម្រាប់ប្រមូលទិន្នន័យ គឺជាកម្រងសំណួរ ផ្នែកតី១ដែលពាក់ព័ន្ធនឹងព័ត៌មានអំពីស្ថានភាពទូទៅរបស់លោកគ្រូអ្នកគ្រូ មានដូចជា ភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍បង្រៀន។ ផ្នែកទី២ ទស្សនៈគ្រូបង្រៀនទៅលើការអនុវត្តឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព។ ស្ថិតិដែលប្រើក្នុងការវិភាគទិន្នន័យមានដូចជា ភាគរយ តម្លៃមធ្យម គម្លាតស្តង់ដា Independent Sample t-test និងOne-way ANOVA ។

លទ្ធផលសំខាន់ៗនៃការសិក្សាស្រាវជ្រាវនេះ អាចសរុបបានដូចខាងក្រោម៖

១- ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាព តាមទស្សនៈរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញ ជារួមស្ថិតក្នុងកម្រិត "**ខ្ពស់**"។ ពេលពិចារណាតាមផ្នែក លទ្ធផលស្ថិតក្នុងកម្រិត "**ខ្ពស់**" គ្រប់ផ្នែក។ បើលំដាប់តម្លៃមធ្យមពីខ្ពស់មកទាប គឺផ្នែកអត្តទត្តបុគ្គល ស្ថិតក្នុងលំដាប់ទី១ តាមដោយផ្នែកនិយ័តភាពការងារ ស្ថិតក្នុងលំដាប់លេខ២ បន្តមកផ្នែកមនុស្សធម៌ការងារ ស្ថិតក្នុងលំដាប់លេខ៣ បន្ទាប់មកផ្នែកឧត្តមគតិការងារ ស្ថិតក្នុងលំដាប់លេខ៤ និងផ្នែកភាពបម្រុងប្រយ័ត្ន ស្ថិតក្នុងលំដាប់លេខ៥។ ឥរិយាបថភាពជាពលរដ្ឋសកលក្នុងអង្គភាពរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យដោយបែងចែកតាមភេទ អាយុ គុណវុឌ្ឍិ និងបទពិសោធន៍បង្រៀន ស្ថិតក្នុងកម្រិត "**ខ្ពស់**"។

២- លទ្ធផលប្រៀបធៀបឥរិយាបថភាពជាពលរដ្ឋសកលរបស់គ្រូបង្រៀនកម្រិតវិទ្យាល័យក្នុងរាជធានីភ្នំពេញដែលមានភេទដូចគ្នាបានបង្ហាញឱ្យឃើញថា គ្រូបង្រៀនដែលមានភេទដូចគ្នាមានការយល់ឃើញខុសគ្នាយ៉ាងមានសារៈសំខាន់ផ្នែកស្ថិតតិក្នុងកម្រិត ០.០១ ចំណែកឯផ្នែកដទៃទៀតមិនខុសគ្នានោះទេ។ បើធ្វើការប្រៀបធៀបទៅលើអាយុវិញនោះ លទ្ធផលបង្ហាញថា ផ្នែកនិយ័តភាពការងារមានភាពខុសគ្នាយ៉ាងមានសារៈសំខាន់ផ្នែកស្ថិតតិក្នុងកម្រិត ០.០១ ឯផ្នែកទាំង៤ទៀត ពុំមានភាពខុសគ្នានោះទេ។ បន្ថែមពីនេះទៅទៀត បើយើងមើលទៅលើលទ្ធផលប្រៀបធៀបទៅលើកម្រិតគុណវុឌ្ឍិគ្រូបង្រៀនវិញ នោះយើងឃើញា ការយល់ឃើញគ្រប់ផ្នែកទាំង៥របស់គ្រូបង្រៀនគឺមានភាពដូចគ្នា។ រីឯការបង្រៀបធៀបទៅតាមបទពិសោធន៍បង្រៀនវិញ លទ្ធផលបង្ហាញឱ្យឃើញថាផ្នែកនិយ័តភាពការងារ ផ្នែកបម្រុងប្រយ័ត្ន និងផ្នែកមនុស្សធម៌ការងារមានភាពខុសគ្នាយ៉ាងមានសារៈសំខាន់ផ្នែកស្ថិតិក្នុងកម្រិត ០.០១ ចំណែកឯ២ផ្នែកដទៃផ្សេងទៀតគឺ ផ្នែកឧត្តមគតិការងារ និងផ្នែកអត្តទត្តបុគ្គលមិនមានភាពខុសគ្នានោះទេ។

## ៥.២- សេចក្តីសន្និដ្ឋាន

